# គិហិបដិបត្តិ

## បទនមស្សការ

ពិស្ដា នឹង សង្ខេប



វត្តពុទ្ធរង្សីម៉ែលប៊ន

២២៧.
៧

ព.ស ២៥៣៧ គ.ស ១៩៩៣

Wat Buddharangi Melbourne Vic. Australia

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។


សូមថ្លែងអំណរគុណដល់

**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។


Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.


A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.


www.budinst.gov.kh        www.elibraryofcambodia.org

២២៧.៧

# គិហិបដិបត្តិ

## មានបទនមស្សការ

ពិស្តា នឹង សង្ខេប

ប្រមូលចងក្រង

ដោយ

ព្រះភិក្ខុស្រី សុវណ្ណ ចារុវណ្ណោ

វត្តពុទ្ធរង្សីម៉ែលប៊ន

រដ្ឋវិចតូរីយ៉ា អូស្ត្រាលី

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE
៥៥៥/៩៥
14.8

បោះពុម្ព ចំនួន ២០០០ ក្បាល

ព.ស ២៥៣៧ គ.ស ១៩៩៣

# មាតិកាធម៌

ឈ្មោះធម៌ | លេខទំព័រ

កថាមុខ ........................................ ក

ពុទ្ធរតនប្បណាមគាថា ........................................ ១

ធម្មរតនប្បណាម ........................................ ៥

សង្ឃរតនប្បណាម ........................................ ៨

ត្រៃបណាមសង្ខេប ........................................ ១២

បណាមគាថា ........................................ ១៤

នមស្សការព្រះពុទ្ធ ២៨ ព្រះអង្គ ........................................ ១៧

នមស្សការបូជនីយវត្ថុ ........................................ ២០

បណាមគាថាពុទ្ធិកបឋមសិក្សា ........................................ ២១

សុខាភិយាចនគាថា ........................................ ២៣

មង្គលសុត្ត ប្រែកាព្យ ........................................ ២៤

បរាភវសុត្ត ប្រែកាព្យ ........................................ ២៩

ពុទ្ធជយមង្គលគាថា ........................................ ៣៦

នមស្សការព្រះពុទ្ធបាទ ........................................ ៤០

បច្ឆិមពុទ្ធវចនៈ ........................................ ៤២

ធម៌សុខោ ........................................ ៤៤

សរណប្បទីបិកាគាថា ........................................ ៤៦

ទលិទ្ទសុត្តគាថា ........................................ ៤៨

គារវសុត្តគាថា ........................................ ៤៩

ផ្សាយមេត្តាក្នុងទិសទាំង ១០ ........................................ ៥០
រំលឹកគុណូបការៈ ........................................ ៥២
គាថាសូមសេចក្តីសុខ ........................................ ៥៣
បត្តិទានគាថា ( យាទេវតា ) ........................................ ៥៥
បត្តិទានគាថា ( ឥមិនា ) ........................................ ៥៧
ខមាបនគាថា ........................................ ៥៩
បត្តិទានគាថា ( យំកិញ្ចិ ) ........................................ ៦០
រតជៈខ្ញុំសាង ........................................ ៦២
ឧទ្ទិសកុសលដោយបទសង្ខេប ........................................ ៦៣
សុភមង្គលគាថា ........................................ ៦៤
វិធីសមាទាននិច្ចសីល ........................................ ៦៦
វិធីសមាទានឧបោសថសីល ........................................ ៧២
ពិធីកម្មក្នុងពុទ្ធសាសនា ........................................ ៧៩
ភត្ត ១៤ យ៉ាង ........................................ ៨០
បាលីវេរភត្ត ........................................ ៨២
ឈ្មោះសំពត់ ១០ យ៉ាង ........................................ ៨៩
ឈ្មោះសេនាសនៈ ........................................ ៩០
ឈ្មោះវត្ថុ ........................................ ៩១
អង្គនិច្ចសីល នឹង ឧបោសថសីល ........................................ ៩២
អកុសលកម្មបថ ១០ យ៉ាង ........................................ ៩៥
អង្គអកុសលកម្មបថ ១០ ........................................ ៩៦
កុសលកម្មបថ ១០ យ៉ាង ........................................ ៩៨

# កថាមុខ

សៀវភៅតិហិបដិបត្តិនេះ ខ្ញុំបានប្រមូលឯកសារផ្សេងៗក្នុងច្បាប់ចាស់ដែលនៅមានសេសសល់មកបោះពុម្ពសាឡើងវិញ នឹងមានបន្ថែមសុត្តបទខ្លះ គោលបំណងដើម្បីតម្រូវតាមសេចក្តីត្រូវការរបស់ពុទ្ធបរិស័ទ ដែលខ្វះខាតក្នុងកាលសម័យនេះ ហើយខ្ញុំសូមអភ័យទោសចំពោះអស់លោកអ្នកអាន អ្នកសិក្សា អ្នកប្រាជ្ញ បណ្ឌិតកវី មេត្តាជួយកែជួយបំពេញន័យក្រែងមានភ្លាំងភ្លាត់ ចាត់ពាក្យ ខុសអក្ខរាវិរុទ្ធិ ព្រោះអាស្រ័យវាយអក្សរម៉ាស៊ីនកុំព្យូទ័រ ដែលខ្ញុំបានព្យាយាមរចនាអក្សរផ្ចិតបោះចេញមកធ្វើជាសៀវភៅតូចមួយសម្រាប់អស់លោកអ្នកសិក្សាក្នុងព្រះពុទ្ធសាសនា ដើម្បីរក្សានូវវប្បធម៌អក្សរសាស្ត្រជាតិ ឱ្យមានពំនឹងឡើងវិញ ជាពិសេសគឺព្រះពុទ្ធសាសនាដែលសាបសូន្យម្តងមកហើយក្នុងប្រទេសកម្ពុជាយើងនេះ ក្នុងសម័យកាលលទ្ធិកុម្មុយនិស្តចូលស្រុក ហើយបច្ចុប្បន្នព្រះពុទ្ធសាសនាកំពុងមានជីវិតនឹងសកម្មភាពឡើងវិញដោយសន្សឹមៗ ទោះបីមានការខ្វះខាតក្បួនច្បាប់សម្រាប់សិក្សាយ៉ាងណាក្តី ក៏យើងទាំងអស់គ្នាខិតខំស្រាវជ្រាវប្រមូលរកឯកសារដែលមាននៅសេសសល់ក្នុងប្រទេសនឹងក្រៅប្រទេស មកចងក្រងជាក្បួនច្បាប់សម្រាប់កុលបុត្រខ្មែរយើងសិក្សាបន្ត សូមឱ្យព្រះសទ្ធម្មរបស់ព្រះមានព្រះភាគតាំងនៅអស់កាលជាយូរអង្វែងតទៅ ។ ដោយសេចក្តីព្យាយាមនេះ សូមឧទ្ទិសកុសលជូនចំពោះបុព្វការីជនមានមាតាបីតា នឹងញាតិការទាំង ៧សន្តាន ចូរបាននូវសេចក្តីសុខចំរើនគ្រប់គ្នាកុំបីខាន ។

វត្តពុទ្ធរង្សីម៉ៃលបិនថ្ងៃចន្ទ១៤កើតខែមិគ្គសិរឆ្នាំរកាបញ្ចស័កព.ស ២៥៣៧

ព្រះស្រី សុវណ្ណ ចារុវណ្ណោ

# ធម៌នមស្សការ

## រតនបូជា

**ឥមេហិ ទីបធូបាទិសក្ការេហិ**

**ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ**

ប្រែថា- ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះ ពុទ្ធ ព្រះធម៌ព្រះសង្ឃ ជាម្ចាស់ដោយគ្រឿងសក្ការៈទាំងឡាយ មានទៀននិងធូបជាដើមនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាល. ជាអង្វែង ទៅហោង ។

## ពុទ្ធរតនប្បណាម

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

( សូត្រ ៣ ដង )

ប្រែថា-វីកិរិយានមស្សការថ្វាយបង្គំ នៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅ ព្រះអង្គឡើយ ។ (ថ្វាយបង្គំម្តង)

**យោ សន្និសិន្នោ វរពោធិមូលេ**
**មារំ សសេនំ មហតឹ វិជេយ្យោ**
**សម្ពោធិមាគច្ឆិ អនន្តញាណោ**
**លោកុត្តមោ តំ បណមាមិ ពុទ្ធំ**

ប្រែថា- ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចំរើននូវព្រះអានាបានស្សតិកម្មដ្ឋាន លើរតនបល្ល័ង្កក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិ-ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះដោយគោរព ។

( ថ្វាយបង្គំម្តង )

**យេ ច ពុទ្ធា អតីតា ច យេ ច ពិទ្ធា អនាគតា**
**បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា**

ប្រែថា- ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្តី, ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្រក័ល្បនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ គ្រប់កាលទាំងពួង ។

(ក្រាបថ្វាយបង្គំម្តង)

**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជា-ចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិ-សទម្មសារថិ សត្ថាទេវមនុស្សានំ ពុទ្ធោ ភគវាតិ**

ប្រែថា- **ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគនោះទ្រង់ព្រះនាមថា **អរហំ** ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺកិលេស ព្រមទាំងវាសនាគឺកាយបយោគនឹងវចីបយោគ, **សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ, **វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា **វិជ្ជាចរណសម្បន្នោ** ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជ ៣ នឹងវិជ្ជា ៨ និងចរណៈ ១៥, **សុគតោ** ទ្រង់ព្រះនាមថា **សុគតោ** ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថាន គឺអមតៈមហានិព្វាន, **លោកវិទូ** ទ្រង់ព្រះនាមថា **លោកវិទូ** ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក, **អនុត្តរោ** ទ្រង់ព្រះនាមថា **អនុត្តរោ** ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើរគ្មាន, **បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា **បុរិសទម្មសារថិ** ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន, **សត្ថាទេវមនុស្សានំ** ទ្រង់ព្រះនាមថា **សត្ថាទេវមនុស្សានំ** ព្រោះព្រះអង្គជាសស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ, **ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញុំាងអ្នកដទៃឲ្យត្រាស់ដឹងផង,

**គតោ** ទ្រង់ព្រះនាមថា **គតោ** ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ចាក់ចោលហើយ គឺថាព្រះអង្គលែងត្រឡប់ កើតទៀតហើយ ។

( ក្រាបថ្វាយបង្គំម្តង)

រួចហើយត្រូវប្រកាសប្តេជ្ញាខ្លួនចំពោះពុទ្ធគុណថា

**នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ**

ប្រែថា- **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរលឹកនៃខ្ញុំព្រះករុណាមិនមានឡើយ **ពុទ្ធោ មេ សរណំ វរំ** មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹងទីរលឹកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចនេះ ។

( ក្រាបថ្វាយបង្គំម្តង)

រួចហើយត្រូវសូមខមាទោសនឹងព្រះពុទ្ធគុណដូច្នេះថា

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ**

**ពុទ្ធេ យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ**

ប្រែថា- **ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវល្អងធូលីព្រះបាទនៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈដ៏ឧត្តមគឺត្បូង **ពុទ្ធេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណា

ធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់ **ពុទ្ធោ ខមតុ តំ មមំ** សូមព្រះពុទ្ធជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

( ក្រាបថ្វាយបង្គំម្តង)

## ធម្មវន្ទនប្បណាម

**អដ្ឋង្គិការិយបថោ ជនានំ**
**មោក្ខប្បវេសាយ ឧជូ ច មគ្គោ**
**ធម្មោ អយំ សន្តិករោ បណីតោ**
**និយ្យានិកោ តំ បណមាមិ ធម្មំ**

ប្រែថា- ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញ៉ាំងជនដែលប្រាថ្នានូវព្រះនិព្វាន ឲ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះជាធម៌ធ្វើឲ្យត្រជាក់ រម្ងាប់បង់នូវភ្លើងទុក្ខភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញ៉ាំងសត្វឲ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះ ដោយគោរព ។

( ក្រាបថ្វាយបង្គំម្តង )

**យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា**
**បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា**

ប្រែថា- ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ និងមានមកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណា សីមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះ គ្រប់កាលទាំងពួង ។

( ក្រាបថ្វាយបង្គំម្តង )

## ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហិ

ប្រែថា- **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដកជាធម៌គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដែងហើយដោយល្អ (ធម្មោ ព្រះនព្វលោកុត្តរធម៌មាន ៩ ប្រការគឺមគ្គ ៤ ផល ៤ និព្វាន ១ ) **សន្ទិដ្ឋិកោ** ជាធម៌គឺព្រះអរិយបុគ្គលទាំងពួង ដឹងពិត ឃើញពិតដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយស្តាប់ដោយជឿបិគ្គលដទៃនោះៗ ក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង **អកាលិកោ** ជាធម៌ឲ្យផលមិនរង់ចាំកាល គឺថាបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ **ឯហិបស្សិកោ** ជាធម៌គួរដល់ ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនិងហៅបុគ្គលដទៃឲ្យចូលមកមើលបាន **ឱបនយិកោ** ជាធម៌គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយ

អំណាចនៃភាវនា **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើមគប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

( ក្រាបថ្វាយបង្គំម្តង )

រួចហើយត្រូវប្រកាសប្តេជ្ញាខ្លួនចំពោះធម៌គុណថា

**នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ**

ប្រែថា- **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរលឹកនៃខ្ញុំព្រះករុណាមិនមានឡើយ **ធម្មោ មេ សរណំ វរំ** មានតែព្រះធម៌ជាម្ចាស់ជាទីពឹងទីរលឹកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចនេះ ។

( ក្រាបថ្វាយបង្គំម្តង )

រួចហើយត្រូវសូមខមាទោសនិងព្រះធម្មគុណថា

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ**

**ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ**

ប្រែថា- **ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ** ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរ មានពីរប្រការ គឺព្រះបរិយត្តិធម៌និងព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តម គឺត្បូង **ធម្មេ យោ ខលិតោ**

**ពោរសោ** ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះធម៌ជាម្ចាស់ **ធម្មោ ខមតុ តំ មមំ** សូមព្រះធម៌ជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំ ព្រះករុណា ។

( ក្រាបថ្វាយបង្គំម្តង )

# សង្ឃានុស្សតិ

**សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ**
**សន្តិន្ទ្រិយោ សព្វមលប្បហីនោ**
**គុណេហិនេកេហិ សមិទ្ធិបត្តោ**
**អនាសវោ តំ បណមាមិ សង្ឃំ**

ប្រែថា- ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធិវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រីយរម្ងាប់ហើយ មានមន្ទិលគឺរាគាទិក្កិលេសទាំងពួងបន្សាត់បង់ហើយ ជាព្រះសង្ឃមានអាសវៈធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះអរិយសង្ឃនោះ ដោយគោរព ។

( ក្រាបថ្វាយបង្គំម្តង )

**យេ ច សង្ឃា អតីតា ច យេ សង្ឃា អនាគតា**

ប្រែថា-ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ

និងផលកន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃនិងបានសម្រេចមគ្គនិងផលក្នុងកាលខាងមុខក្តី, ព្រះសង្ឃទាំងឡាយឯណាដែលជាព្រះសង្ឃបានសម្រេចមគ្គនិងផលក្នុងកាលបច្ចុប្បន្ននេះក្តី, ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយនោះគ្រប់កាលទាំងពួង ។

( ក្រាបថ្វាយបង្គំម្តង )

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ**
**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ**
**ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ**
**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ**
**យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា**
**ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ**
**បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ**
**អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។**

ប្រែថា- **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តហើយដោយប្រពៃ គឺប្រតិបត្តតាមគន្លងព្រះនព្វលោកុត្តរធម៌, **ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តដោយត្រង់ គឺប្រតិបត្តជា

មជ្ឈិមប្បដិបទា, **ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ពានក្បៀមផុតចាកទុក្ខទាំងពួង, **សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តគួរដល់សីល សមាធិ បញ្ញា, **យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយមាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គនិងសោតាបត្តិផលជាគូ ១, សកទាគាមិមគ្គនិងសកទាគាមិផល ១, អនាគាមិមគ្គនិងអនាគាមិផលជាគូ ១, អរហត្តមគ្គនិងអរហត្តផលជាគូ ១, **អដ្ឋ បុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ ១, សោតាបត្តិផល ១, សកទាគាមិមគ្គ ១, សកទាគាមិផល ១, អនាគាមិមគ្គ ១, អនាគាមិផល១, អរហត្តមគ្គ ១, អរហត្តផល ១, **ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនុ៎ះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ, **អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា, **បាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបិគ្គលតាក់តែងដើម្បីញាតិនិងមិត្រ ដែលមកអំពីទិសផ្សេង ៗ ហើយបង្អោនចូលមកបូជា, **ទក្ខិណេយ្យោ** លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្មនិងផលហើយបូជា, **អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ, **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជា

ទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន ។

( ក្រាបថ្វាយបង្គំម្តង )

តទៅគប្បីប្រកាសប្តេជ្ញាខ្លួនចំពោះសង្ឃគុណថា

**នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ**

ប្រែថា- **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរលឹកនៃខ្ញុំព្រះករុណាមិនមានឡើយ **សង្ឃោ មេ សរណំ វរំ** មានតែព្រះសង្ឃជាម្ចាស់ជាទីពឹងទីរលឹកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គលចូលមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យ សច្ចៈនេះ ។

( ក្រាបថ្វាយបង្គំម្តង )

រួចហើយត្រូវសូមខមាទោសនិងសង្ឃគុណថា

**ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ**

**សង្ឃេ យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ**

ប្រែថា- **ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសង្ឃ ដ៏ប្រសើរមានពីរប្រការ គឺ សម្មតិសង្ឃនិងអរិយសង្ឃ ដោយអវយវៈដ៏ឧត្តមគឺត្បូង, **សង្ឃេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះសង្ឃជាម្ចាស់, **សង្ឃោ**

**ខមតុ តំ មមំ** សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំ ព្រះករុណា ។

( ក្រាបថ្វាយបង្គំម្តង )

## ត្រៃបណាមសង្ខេបព្រមទាំងបូជាគ្រឿងសក្ការៈ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

( ប្រែដូចមុន )

**ឥតិបិ សោ ភគវា អរហំ ។ល។ ភគវាតិ,**

**តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ**

**តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

ប្រែថា- **ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា **អរហំ** ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺកិលេសព្រមទាំងវាសនា គឺកាយបយោគ និង វចីបយោគ ។ល។ **ភគវា** ទ្រង់ព្រះនាមថា **ភគវា** ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ **តំ អរហា ទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រកបហើយដោយគុណ មានគុណថា **អរហំ** ជាដើមនោះ ដោយសិរសាគឺត្បូង **តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ ។ (ក្រាបថ្វាយបង្គំម្តង )

**ស្វាក្ខាតោ ភគវតា ធម្មោ ។ល។ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

ប្រែថា- **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌គរព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងហើយដោយល្អ ។ល។ **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន, **តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណមានគុណថា **ស្វាក្ខាតោ** ជាដើមនោះដោយសិរសាគឺត្បូង **តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះធម៌ជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណ ប៉ុណ្ណេះ ។

( ក្រាបថ្វាយបង្គំម្តង )

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ ។ល។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

ប្រែថា- **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះ

ដ៏មានព្រះភាគលោកប្រតិបត្តហើយដោយប្រពៃ គឺប្រតិបត្តតាមគន្លងព្រះនព្វលោកុត្តរៈធម៌ ។ល។ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបិញ្ញក្ខេត្តគឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន **តំ សុបដិបន្នាទិគុណសហិតំ សង្ឃំ សិរសា នមាមិ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសង្ឃជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណមានគុណថា **សុបដិបន្នោ** ជាដើមនោះ ដោយសិរសាគឺត្បូង **អហំ សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសង្ឃជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណ ប៉ុណ្ណេះ ។

( ក្រាបថ្វាយបង្គំម្តង )

## បណាមគាថា

**យោ កប្បកោដីហិបិ អប្បមេយ្យំ**

**កាលំ ករោន្តោ អតិទុក្ករានិ**

**ខេទំ គតោ លោកហិតាយ នាថោ**

**នមោ មហាការុណិកស្ស តស្ស ។**

**អសម្ពុធំ ពុទ្ធនិសេវិតំ យំ ភវាភវំ គច្ឆតិ**

**ជីវលោកោ នមោ អវិជ្ជាទិកិលេសជាលំ**

**វិទ្ធំសិនោ ធម្មវរស្ស តស្ស ។**

**គុណេហិ យោ សីលសមាធិបញ្ញា វិមុត្តិញាណប្បភូតីហិ យុត្តោ ខេត្តំ ជនានំ កុសលត្ថិកានំ តមរិយសង្ឃំ សិរសា នមាមិ ។**

ប្រែថា- **យោ ធម្មរាជីហិបិ អប្បមេយ្យំ កាលំ ករោន្តោ អតិទុក្ករានិ ខេទំ គតោ លោកហិតាយ នាថោ នមោ មហាការុណិកស្ស តស្ស** ព្រះពុទ្ធជាទីពឹងជាពំនឹងសព្វសត្តា ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ ។ រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគួរ បានត្រាស់ជាសព្វញ្ញូច្បាស់ជាគ្រូលើភពឋាន ។ ធ្វើកម្មជាកម្រ មនុស្សនិករត្រាប់ពុំបាន តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៍ដល់សព្វសត្វ ។ ខ្ញុំសូមឱនសិរសាចិត្តប្រាថ្នាបង្គំថ្វាត់ ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល ។

**អសង្ខតំ ពុទ្ធនិសេវិតំ យំ គតាគតំ ឆិន្ទតិ វីតសោកោ នមោ អវិជ្ជាទិកិលេសជាលវិទ្ធំសិនោ ធម្មវរស្ស តស្ស** សត្វតែងកើតស្លាប់បង់ ព្រោះចំណង់កម្មជាគោល ឲ្យវិលវល់អន្ទោល ក្នុងភពតូចនិងភពធំ ។ ហេតភតែមឹននឹងធម៌ជាម្ចាស់ល្អស្អាតសុខុម ព្រះពុទ្ធតែងសេពសម ចិត្តខ្ញុំសូមនមស្សការ ។ នូវធម៌ប្រពៃពីត វិសេសសុទ្ធនោះឯកណា កាត់បង់នូវអវិជ្ជា គឺបណ្ដាញកិលេសហើយ ។

**គុណេហិ យោ សីលសមាធិបញ្ញា វិមុត្តិញាណប្បភូតីហិ យុត្តោ ខេត្តំ ជនានំ កុសលត្ថិកានំ តមរិយសង្ឃំ សិរសា នមាមិ** ព្រះសង្ឃអង្គសាវ័ក មានសំវរៈសទ្ធា

ទ្រង់ កបដោយគុណសីលត្រង់ និងសមាធិបញ្ញា ។ និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល។ ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល ជាបុត្តព្រះទសពល ជាមង្គលដល់សព្វសត្វ ។

## នមស្សការសុំសេចក្ដីសុខ

**និរុត្តមមច្ចុត្តំ នមស្សនេយ្យំ នមស្សមានោ រតនត្តយំ យំ**

**បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ តស្សានុភាវេន ហតន្តរាយោ**

ខ្ញុំសូមនមស្សការ លើកហត្ថាឱនសិរសី បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា។ សូមបុណ្យកងកុសល ឲ្យបានដល់យើងខ្ញុំណា ពេញពោរស្មើធារា ដូចជលសាធំទូលាយ ។ សូមឲ្យកំចាត់បង់ អពមង្គលទាំងឡាយ ឲ្យចៀសចេញចាកឆ្ងាយ ក្ដីអន្តរាយកុំមាន ។ ដោយកំលាំងអានុភាព បុញ្ញលាភជាប្រធាន កងបុណ្យរាសីមាន សូមបានក្សាន្តកុំមានមោះ ។ ដោយគុណនមស្សការ ត្រៃរតនាប្រសើរខ្ពស់ សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វានហោង ។

( ក្រាបថ្វាយបង្គំម្ដង )

## នមស្សការចំពោះព្រះសម្ពុទ្ធ២៨ព្រះអង្គ

វន្ទេ តណ្ហង្ករំ ពុទ្ធំ　　វន្ទេ មេធង្ករំ មុនឹ
សរណង្ករំ មុនឹ វន្ទេ　　ទីបង្ករំ ជិនំ នមេ
វន្ទេ កោណ្ឌញ្ញសត្ថារំ　　វន្ទេ មង្គលនាយកំ
វន្ទេ សុមនសម្ពុទ្ធំ　　វន្ទេ រេវតនាយកំ
វន្ទេ សោភិតសម្ពុទ្ធំ　　អនោមទស្សិំ មុនិ នមេ
វន្ទេ បទុមសម្ពុទ្ធំ　　វន្ទេ នារទនាយកំ
បទុមុត្តរំ មុនឹ វន្ទេ　　វន្ទេ សុមេធនាយកំ
វន្ទេ សុជាតសម្ពុទ្ធំ　　បិយទស្សិំ មុនិ នមេ
អត្ថទស្សិំ មុនឹ វន្ទេ　　ធម្មទស្សិំ ជិនំ នមេ
វន្ទេ សិទ្ធត្ថសត្ថារំ　　វន្ទេ តិស្សមហាមុនិ
វន្ទេ ផុស្សមហាវីរំ　　វន្ទេ វិបស្សិនាយកំ
សិខិ មហាមុនិ វន្ទេ　　វន្ទេ វេស្សភុនាយកំ
កកុសន្ធំ មុនឹ វន្ទេ　　វន្ទេ កោនាគមនំ ជិនំ
កស្សបំ សុគតំ វន្ទេ　　វន្ទេ គោតមនាយកំ

**អដ្ឋវីសតិមេ ពុទ្ធា និព្វានមគ្គទាយកា**
**នមេ តេ សិរសា និច្ចំ តេ មំ រក្ខន្តុ សព្វទា ,**

ខ្ញុំសូមបង្គំព្រះបរមសម្ពុទ្ធ មានព្រះនាមប្រាកដព្រះតណ្ហង្ករ
ខ្ញុំសូមបង្គំព្រះបរមបវរ ព្រះមេធង្ករជាសម្ពុទ្ធា ។
សូមក្រាបបង្គំប្រណម្យវន្ទា នូវព្រះភគវាព្រះសរណង្ករ
សូមថ្វាយបង្គំព្រះទីបង្ករ មានញាណបវរបារមីពោរពេញ ។
សូមថ្វាយបង្គំនូវព្រះកោណ្ឌញ្ញ ព្រះអង្គបំពេញធម៌ជាកុសល
ខ្ញុំសូមបង្គំនូវព្រះទសពល ព្រះនាមមង្គលជាសម្ពុទ្ធៈ ។
ខ្ញុំសូមបង្គំប្រណមគារវៈ ព្រះនាមសុមនៈសម្មាសម្ពុទ្ធ
ខ្ញុំសូមបង្គំព្រះបរមសុគត ព្រះនាមប្រាកដព្រះរេវតៈ ។
ខ្ញុំសូមបង្គំព្រះបរមពុទ្ធៈ មានញាណសោភៈព្រះនាមសោភិត
ខ្ញុំសូមបង្គំប្រណម្យប្រណិត ឆ្ពោះព្រះវិជិតអនោមទស្សី ។
ខ្ញុំសូមក្រាបថ្វាយឱនកាយសិរសី ចំពោះព្រះមុនីព្រះនាមបទុម
ខ្ញុំសូមឱនកាយថ្វាត់ថ្វាយបង្គំ ចំពោះព្រះបរមព្រះនាមនារទៈ ។
សូមថ្វាយបង្គំព្រះបទុមុត្តរៈ មានញាណសោភវរពុទ្ធា
ខ្ញុំសូមបង្គំនូវព្រះភគវា ទ្រង់ព្រះនាមាសុមេធសម្ពុទ្ធ ។
ខ្ញុំសូមបង្គំប្រណម្យក្រាបលុត ឆ្ពោះព្រះសម្ពុទ្ធព្រះនាមសុជាត
ខ្ញុំសូមបង្គំប្រណម្យអភិវាទ ឆ្ពោះព្រះមុនីនាថបិយទស្សី ។
ខ្ញុំសូមបង្គំឆ្ពោះព្រះជិនស្រី អត្ថទស្សីបារមីខ្ពង់ខ្ពស់

ខ្ញុំសូមបង្គំឆ្ពោះព្រះទ្រង់យស ព្រះនាមចំពោះធម្មទស្សី ។
ខ្ញុំសូមបង្អោនលំទោនសិរសី បង្គំជិនស្រីព្រះនាមសិទ្ធត្ថ
ខ្ញុំសូមបង្គំនូវព្រះមុនីរតន៍ ព្រះនាមប្រាកដតិស្សសាស្តា ។
ខ្ញុំសូមបង្គំនូវព្រះសម្មា- សម្ពុទ្ធនាមថាផុស្សៈមុនី
ខ្ញុំសូមបង្គំប្រណម្យអញ្ជលី ឆ្ពោះព្រះមុនីព្រះនាមវិបស្សី ។
សូមថ្វាយបង្គំបរមជិនស្រី ព្រះនាមសិខីសរពេជ្ញពុទ្ធា
ខ្ញុំសូមឱនកាយក្រាបថ្វាយវន្ទា ឆ្ពោះព្រះភគវាព្រះនាមវេស្សភូ
ខ្ញុំសូមបង្គំលើកហត្ថទាំងគូ ឆ្ពោះព្រះជាគ្រូនាមកកុសន្ធៈ
ខ្ញុំសូមបង្គំប្រណម្យគារវៈ ឆ្ពោះព្រះពុទ្ធៈកោនាគមនោ ។
ខ្ញុំសូមឱនកាយវាចាទន់ទោរ បង្គំពុទ្ធោព្រះនាមកស្សបៈ
ខ្ញុំសូមលំទោនបង្អោនសិរៈ ជាទីគារវៈព្រះនាមគោត្តម ។
គំរបម្ភៃប្រាំបីព្រះបរម សម្ពុទ្ធជាធំកំពូលលោកា
ទូទាំងត្រៃភពជាម្លប់សាខា មនុស្សសត្វទេវតាមារព្រហ្មទាំងឡាយ។
ដែលបានចូលជ្រកក្រោមម្លប់ព្រះឆាយ បានសុខសប្បាយគ្រប់រូបរាល់គ្នា
បានទៅសោយសុខក្នុងឋានសួគ៌ា ឬឋានព្រហ្មានឹងព្រះនិព្វាន ។
ដោយបុណ្យបារមីនៃព្រះទ្រង់ញាណ ព្រះធម៌ប្រធានជាយាននាំសត្វ
តេជៈយើងខ្ញុំប្រណម្យថ្វាយថ្វាត់ នូវព្រះពុទ្ធរ័តន៍គ្រប់ ៗ ព្រះអង្គ ។
ព្រមទាំងព្រះធម៌នឹងព្រះអរិយសង្ឃ សាវ័កគ្រប់អង្គម្ភៃប្រាំបី
ខ្ញុំសូមអានុភាពពីព្រះជិនស្រី ម្ភៃប្រាំបីព្រះអង្គនោះឯង ។
ព្រមទាំងព្រះធម៌ព្រះអង្គសំដែង ទាំងព្រះគម្ពែងសង្ឃជាសាវ័ក

សូមសុខចំរើនកើតឡើងតាមថ្នាក់ កុំឲ្យមានអាក់រៀងរាល់ជាតា ។
សូមឲ្យខ្ញុំបានដល់ឋានទេវតា ដូចក្ដីប្រាថ្នាកុំបីឃ្លៀងឃ្លាត
មានព្រះនិព្វានជាអវសានជាតិ កុំឲ្យខ្ញុំឃ្លាតពីនិព្វានហោង ។

## ធម៌សូត្រការបូជាចេតិយខត្ត

**វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុ បតិដ្ឋិតំ**
**សារីរិកធាតុ មហាពោធិំ ពុទ្ធរូបំ សកលំ សទា ,**

ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតិយ
ព្រមទាំងព្រះសារី- រិកធាតុនៃព្រះពុទ្ធ ។
នឹងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត
លំឥនចិត្តបរិសុទ្ធ លើកកំបង់អញ្ជលី ។
និងព្រះពុទ្ធរូប ដំណាងអង្គព្រះមុនី
ដែលឋិតនៅគ្រប់ទី ឋាននានានោះទាំងអស់ ។
ដោយតេជៈនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរំលស់ រំដោះទុក្ខភ័យអន្តរាយ ។
សូមឲ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ
សត្រូវទោះជិតឆ្ងាយ សូមឲ្យក្លាយមកជាមិត្រ ។
សូមទាន់ព្រះអរិ- យមេត្រេយ្យថ្លៃវិសិដ្ឋ
សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង ។

## បណាមគាថា

សម្រាប់សិស្សសាលាពុទ្ធិកបឋមសិក្សា សូត្រមុនរៀន

**ពុទ្ធោ មហេសិ អរហំ តថាគតោ លោកុត្តរោ សព្វគុហិ វេដ្ឋតោ លោកស្ស សត្ថា ជនតម្ពតោទិតោ វន្ទាមិហំ តំ នរបុង្គវេឈ្យតំ ។**

ប្រែថា-អរហន្តតថាគត ជ្រាបគ្រប់បទស្វែងគុណធំ
ទ្រង់ជាលោកុត្តម ច្បងជាងសព្វគ្រូលើសលន់ ។
ជាសាស្តានៃលោក ចេះឥតស្តោកទូន្មានជន
ខ្ញុំវន្ទាបន្ទន់ ទ្រង់ដែលជនគួរបូជា ។

**ធម្មោ បទីបោ វិយ តស្ស សត្ថុនោ លោកានមន្ទស្ស ចិនាសការកោ សព្វញ្ញុពុទ្ធប្បដត្ថតិ សញ្ញោតោ វន្ទាមហំ តំ នរបុង្គវេឈ្យតំ ។**

ព្រះធម៌នៃសាស្តា ឧបមាដូចពន្លឺ
តែងធ្វើលោកឲ្យភ្លឺ ចាកងងឹតឲ្យសូន្យផុត ។
ដែលប្រាជ្ញសំគាល់អាង ថាតំណាងសព្វញ្ញុពុទ្ធ
ខ្ញុំវន្ទាលំអុត ធម៌នោះសុទ្ធជនបូជា ។

**សង្ឃោ វិសុទ្ធោ សុគតស្ស សាវកោ សិក្ខាសុ ការោ អចម្ពុសិត្ថតោ និទ្ទាបសំសានអនានវោ ចរោ វន្ទាមហំ តំ នរបុង្គវេឈ្យតំ**

សាវ័កព្រះសុគត ស្អាតហ្មតចតវិសេសថ្លា
ប្រាថ្នាត្រៃសិក្ខា លោកសិក្សាធម៌ឧត្តម ។
ជាសង្ឃថ្នាក់ខាងលើ មិនអើពើលោកធម្ម
ខ្ញុំវន្ទាប្រណម្យ សង្ឃឧត្តមជនបូជា ។

**នមការានុភាវេន វឌ្ឍតុ ពុទ្ធសាសនំ**
**សមគ្គាហោតុសង្ឃា ច សុខី ហោន្តុ ច សាធវោ ។**

ដោយអំណាចវន្ទា ត្រៃរតនាជាអម្ចាស់
សូមឲ្យពុទ្ធសាសន៍ លូតលាស់ក្រាស់ចំរើនផង ។
សូមឲ្យសង្ឃព្រមព្រៀង កុំឲ្យល្អៀងខុសគន្លង
សូមសាធុជនផង កុំមានហ្មងបានសុខា ។

**រតនត្តយតេជេន សិក្ខា មេ ជតុ វឌ្ឍនំ**
**តស្សាបិ អានុភាវេន សហាសាវយេច សិជ្ឈតុ ។**

ដោយតេជៈត្រៃរតន៍ ខ្ញុំប្រណិប័តន៍ដោយគោរព
សូមឲ្យការរៀនគ្រប់ របស់ខ្ញុំបានវឌ្ឍនា ។
ដោយអំណាចអានុភាព ដែលខ្ញុំក្រាបថ្វាយវន្ទា
សូមឲ្យការសិក្សា របស់ខ្ញុំសម្រេចឆាប់ ។

**រោគា វេមច្ឆាយា ច ឧប្បន្នា មេ ឧបទ្ទវា**
**ពុទ្ធាទិអានុភាវេន វិនស្សន្តុ អសេសតោ ។**

ដោយអំណាចត្រៃរ័តន៍ មានពុទ្ធរ័តន៍ជាប្រធាន
ប្រសិនបើកើតមាន អន្តរធានចង្រៃរោគ ។

សូមឲ្យវិនាសខ្លោក    កុំសល់រោគតិចតួចឡើយ ។

# ស្វាគីយាចនគាថា

សម្រាប់សិស្សសាលាពុទ្ធិកបឋមសិក្សា សូត្រក្រោយរៀន

**ពុទ្ធំសុមាលិ និបនុត្តមោ តមោ ហន្ត្វាន វោរោចសិត បច្ចំ តថំ**

**មគ្គុត្តរសេលម្ហិ សុចុដ្ឋិតោ ឋិតោ វសោ យំ ចិរំ ឋាតុ សុខំ សទា សទា**

ព្រះពុទ្ធដូចអាទិត្យ    ឧត្តមពិតជាងពួកជន
កំចាត់នូវមោហន្ធ    ហើយចេញចាកសព្វកិលេស ។
ទ្រង់ឋិតនៅលើភ្នំ    ដ៏ឧត្តមមគ្គវិសេស
ដាស់សត្វជាប់កិលេស    ឲ្យភ្លឺថៃសក្នុងលោកា ។
សូមទ្រង់ប្រោសគ្រប់គ្រង    យើងខ្ញុំផងរាល់វេលា
ឲ្យបានសុខគ្រប់គ្នា    អស់កាលយូរអង្វែងទៅ ។

**ស្វាក្ខាតធម្មោ វិមលោ សុនិម្មលោ សន្ទិដ្ឋិកោ សន្តិករោ ធុចង្គរោ**

**បូជារហោ មោក្ខនរោ សុខន្ទរោ សោយំ ចិរំ ឋាតុសុខំ សទា សទា**

ស្វាក្ខាតធម៌ណា    ផ្លូវផង់ថ្លាគ្មានសៅហ្មង
ជាធម៌ដែលអ្នកផង    ឃើញច្បាស់ពិតដោយខ្លួនឯង ។
ធ្វើនូវសន្តិភាព    ធុវភាពដ៏ចិញ្ចែង
គួរបូជាយ៉ាងស្តែង    ឲ្យនិព្វានឲ្យសុខា ។
សូមធម៌នោះគ្រប់គ្រង    យើងខ្ញុំផងរាល់វេលា
ឲ្យបានសុខគ្រប់គ្នា    អស់កាលយូរអង្វែងទៅ ។

**សង្ឃោ វិសុទ្ធោ សុភរោ សយម្ភូរោ ពុទ្ធស្ស បុត្តោ សុជហោ គណញ្ញូហោ ខេត្តញ្ញូនានំ សមណោ សុសាធរោ សោ មំ ចិរំ បាតុ សុខំ សទា សទា ។**

វីព្រះអរិយសង្ឃ ជាបុត្រអង្គព្រះសម្ពុទ្ធ
លោកស្អាតបរិសុទ្ធ ងាយចិញ្ចឹមរៀងរាល់ផ្ទះ ។
ចិញ្ចឹមដោយអាត្មា កិលេសលាលះស្រឡះ
សង្គ្រាមក៏លោកលះ ជ្រះស្រឡះបានក្សេមក្សាន្ត ។
ជាអ្នកស្តាប់ឱវាទ ដែលលោកនាថទ្រង់ទូន្មាន
ជាសាវ័កកល្យាណ ស្រែបុណ្យទាននៃជនា ។
សូមសង្ឃនោះគ្រប់គ្រង យើងខ្ញុំផងរាល់វេលា
ឲ្យបានសុខគ្រប់គ្នា អស់កាលយូរអង្វែងទៅ ។

# មង្គលសូត្រ

**ឯវម្មេ សុតំ** ( សូត្រនេះឈ្មោះថាមង្គលសូត្រ ) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្តាប់មកហើយយ៉ាងនេះថា ,

**ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ** សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវិត្តជេតពនជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី ។
**អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា**

**កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ** លំដាប់នោះឯង ទេវតាអង្គ ១ កាលដែលវេលារាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អ ញុំាំងវត្តជេតពនជុំវិញទាំងអស់ឲ្យភ្លឺស្វាងហើយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងទីណា ក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំចំពោះអង្គព្រះដ៏មានព្រះភាគហើយឈរនៅក្នុងទីដ៏សមគួរ,

**ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ** កាលទេវតានោះឈរក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យជាគាថា ( យ៉ាងនេះ ) ថា :

### តទៅនេះប្រែកាព្យ

**ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ**
**អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ**

ទេព្ដាមនុស្សទាំងឡាយ គិតខ្វល់ខ្វាយរកមង្គល
សូមទានព្រះទសពល ប្រាប់មង្គលដ៏ឧត្ដម ។

**អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា**
**បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ**

ព្រះពុទ្ធទ្រង់ត្រាស់ថា កុំស្នេហាពួកពាលធំ
គួរស្និតបណ្ឌិតសម ហើយឲ្យខំធ្វើបូជា
ដល់លោកអ្នកដែលគួរ ទើបនាំតួទៅសួគ៌ា
ទាំងបីនេះហៅថា ជាមង្គលដ៏ឧត្ដម ។

**បដិរូបទេសវាសោ ច បុព្វេ ច កតបុញ្ញតា**
**អត្តសម្មាបណិធិ ច ឯតម្មង្គលមុត្តមំ**

ការនៅក្នុងប្រទេស ល្អវិសេសឬគួរសម
នឹងមានបុណ្យបានធំ សាងសន្សំទុកពីមុន
ហើយតាំងខ្លួនត្រូវល្អ តាមផ្លូវធម៌ប្រសើរលន់
ទាំងបីនេះជាបុណ្យ ជាមង្គលដ៏ឧត្តម ។

**ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ច សុសិក្ខិតោ**
**សុភាសិតា ច យាវាចា ឯតម្មង្គលមុត្តមំ**

ការបានស្តាប់ធម៌ច្រើន នឹងក្រើនរៀនសីលថ្លៃ
នឹងបានរៀនវិន័យ ឆ្លាត់វៀងវៃជំនាញល្អ
សំដែងសុចរិត សុភាសិតតាមផ្លូវធម៌
ទាំង ៤ យ៉ាងនេះក៏ ជាមង្គលដ៏ឧត្តម ។

**មាតាបិតុ ឧបដ្ឋានំ បុត្តទារស្ស សង្គហោ**
**អនាកុលា ច កម្មន្តា ឯតម្មង្គលមុត្តមំ**

បំរើអ្នកមាតា នឹងបិតាមានគុណធំ
សង្គ្រោះបុត្រភិរម្យ នឹងឧបត្ថម្ភដល់ភរិយា
ធ្វើកិច្ចការអ្វី ៗ ខំឃ្មាត់ខ្មីមិនចោលការ
ទាំង ៤ នេះហៅថា ជាមង្គលដ៏ឧត្តម ។

**ទានញ្ច ធម្មចរិយា ច ញាតកានញ្ច សង្គហោ**
**អនវជ្ជានិ កម្មានិ ឯតម្មង្គលមុត្តមំ**

ការឲ្យវត្ថុទាន ធម៌ក៏បានប្រព្រឹត្តមាំ
សង្គ្រោះញាតិតូចធំ តាមគួរសមទោះជិតឆ្ងាយ
កិច្ចការណាឥតទោស ឬមិនខុសក៏ខ្វល់ខ្វាយ
ទាំង ៤ ដែលអធិប្បាយ ជាមង្គលដ៏ឧត្តម ។

**អារតី វិរតី បាបា មជ្ជបានា ច សញ្ញមោ**
**អប្បមាទោ ច ធម្មេសុ ឯតម្មង្គលមុត្តមំ**

ការលះវាចាបាប សង្រួមភាពកាយរឿយ ៗ
ប្រយ័ត្នមិនធ្វេសឡើយ មិនហ៊ានផឹកទឹកស្រវឹង
ធម៌អាចិ៍ផងទាំងឡាយ មិនមើលប្រមាទខឹង
ទាំង ៣ យ៉ាងនេះសឹង ជាមង្គលដ៏ឧត្តម ។

**គារវោ ច និវាតោ ច សន្តុដ្ឋី ច កតញ្ញុតា**
**កាលេន ធម្មស្សវនំ ឯតម្មង្គលមុត្តមំ**

សេចក្តីគារវៈ ដល់លោកអ្នកដែលគួរផង
បន្ទាបខ្លួនឥតឆ្គង ព្រមទាំងមានក្តីសន្តោស
នឹងមានកតញ្ញូ ចេះស្តាប់ធម៌របស់សប្បុរស
ទាំង ៥ នេះចំពោះ ជាមង្គលដ៏ឧត្តម ។

**ខន្តី ច សោវចស្សតា សមណានញ្ច ទស្សនំ**
**កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ**

សេចក្តីអត់សង្កត់ ធន់អំណត់មិនញាប់ញ័រ
ជាអ្នកមានចិត្តល្អ គេប្រដៅបានដោយងាយ

កាលឃើញពួកសមណៈ គួរសួរធម៌យ៉ាងរីករាយ
ទាំង ៤ ដែលអធិប្បាយ ជាមង្គលដ៏ឧត្តម ។

**តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចាន ទស្សនំ**
**និព្វានសច្ឆិកិរិយា ច ឯតម្មង្គលមុត្តមំ**

ព្យាយាមដុតកិលេស ធម៌វិសេសប្រសើរក្រៃ
ប្រព្រឹត្តល្អប្រពៃ ឃើញអរិយសច្ច ៤
នឹងធ្វើព្រះនិព្វាន ឲ្យច្បាស់បានយ៉ាងមាំមួន
អ្នកធ្វើកិច្ចទាំង ៤ ជាមង្គលដ៏ឧត្តម ។

**ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ**
**អសោកំ វិរជំ ខេមំ ឯតម្មង្គលមុត្តមំ**

ចិត្តនៃបុគ្គលណា មិនជ្រួលមិនញាប់ញ័រ
តាមលោកធម៌ទាំង ៨ ជាចិត្តមានអធ្យោក
មិនសោយសោកប្រាស់ធូលី ជាចិត្តក្សេមពេញទី
ទាំង ៤ នេះជាមង្គល ។

**ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា**
**សព្វត្ថ សោត្ថឹ គច្ឆន្តិ តំ តេសំ មង្គលមុត្តមន្តិ**

មនុស្សឬទេវតា ពួកឯណាមានកុសល
បានធ្វើនូវមង្គល ៣៨ នេះឯង
ពួកនោះមិនថយថោក ខ្ពស់ក្នុងលោកឥតថ្លឹងថ្លែង

| | |
|---|---|
| ហើយបានសុខជាក់ស្ដែង | ប្រាកដក្នុងទីទាំងពួង |
| កាលណោះជាមង្គល | ឧត្តមដល់មនុស្សលោកហោង |
| ព្រមទាំងទេវតាផង | ដោយទំនងយ៉ាងនេះឯង ។ |
| មង្គលអម្បាលនោះ | ព្រះសម្ពុទ្ធទ្រង់សំដែង |
| អត្ថកថាថែង | មនុស្សត្រូវស្វែងរករៀនចុះ ។ |

# បរាភវសុត្តំ

**ឯវម្មេ សុតំ** ( សូត្រនេះឈ្មោះថា បរាភវសូត្រ ) គឺខ្ញុំ (ឈ្មោះ-អានន្ទ ) បានស្ដាប់មកហើយយ៉ាងនេះថា :

**ឯកំសមយំ ភគវា ។ល។ អជ្ឈភាសិ ។**

(( សេចក្ដីប្រែ នឹងបាលីដូចគ្នាក្នុងមង្គលសូត្របទខាងដើម ))

ទេវតាទូលសួរព្រះសាស្ដាថា

**បរាភវន្តំ បុរិសំ មយំ បុច្ឆាម គោតមំ**
**ភវន្តំ បុដ្ឋុមាគម្ម កឹ បរាភវតោ មុខំ**

| | |
|---|---|
| យើងខ្ញុំទាំងឡាយមកសូមទូលសួរ | នូវហេតុដែលគួរចំរើនវិនាស |
| បុរសស្រីក្នុងលោកសន្និវាស | ដែលនឹងវិនាសសាបសូន្យចាកគុណ |
| ត្ដោះព្រះគោតមព្រះអង្គមានបុណ្យ | មេត្ដានិមន្ដសំដែងឲ្យទាន |
| ធម្មជាតដូចម្ដេចដែលជាប្រធាន | នាំសត្វឲ្យមានសេចក្ដីវិនាស ។ |

ព្រះសាស្ដាឆ្លើយតបនឹងទេវតាថា

**សុវិជានោ ភវំ ហោតិ សុវិជានោ បរាភវោ**

**ធម្មកាមោ ភវំ ហោតិ ធម្មទេស្សី បរាភវោ**

អ្នកដែលចំរើនតថាគតស្គាល់ងាយ អ្នកដែលអន្តរាយតថាគតស្គាល់ពិត
អ្នកប្រាថ្នាធម៌ល្អិតល្អក្នុងចិត្ត ហើយខំប្រព្រឹត្តនឹងបានចំរើន
អ្នកដែលទ្រុស្តធម៌ស្អប់ធម៌ឥតកើត ឥតកើតចំរើនវិនាសទៅមុខ ។

**ឥតិ ហេតំ វិជានាម បឋមោ សោ បរាភវោ**

**ទុតិយំ ភគវា ព្រូហិ កិំ បរាភវតោ មុខំ**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទីមួយទាន់ហន់ ។
បពិតព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឲ្យទាន
វិនាសទី ២ អ្វីជាប្រធាន នាំសត្វឲ្យមានសេចក្តីវិនាស ។

**អសន្តស្ស បិយា ហោន្តិ សន្តេន កុរុតេ បិយំ**

**អសតំ ធម្ម រោចេតិ តំ បរាភវតោ មុខំ**

អ្នកដែលស្រឡាញ់ពេញចិត្តស្នេហារ តែនឹងមនុស្សណាអសប្បុរស
តែងមិនស្រឡាញ់ពេញចិត្តទាំងអស់ នឹងអ្នកសប្បុរសមកធ្វើជាមិត្រ ។
សេចក្តីស្រឡាញ់ពេញចិត្តគំនិត ហើយទៅគប់មិត្តអសប្បុរស
គាប់ចិត្តក្នុងធម៌ឬមួយរបស់ ហេតុនោះទាំងអស់នាំឲ្យវិនាស ។

**ឥតិ ហេតំ វិជានាម ទុតិយោ សោ បរាភវោ**

**តតិយំ ភគវា ព្រូហិ កិំ បរាភវតោ មុខំ**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនេះឈ្មោះទី ២ ទាន់ហន់ ។

បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឲ្យទាន
វិនាសទី ៣ អ្វីជាប្រធាន នាំសត្វឲ្យមានសេចក្តីវិនាស ។

**និទ្ទាសីលី សភាសីលី អនុដ្ឋាតា ច យោ នរោ**
**អលសោ កោធបញ្ញាណោ តំ បរាភវតោ មុខំ**

អ្នកដេកច្រើនមួយនិយាយច្រើនមួយ នឹងអ្នកឥតព្យាយឥតគិតប្រឹងប្រែង
អ្នកខ្ជិលច្រអូសមិនមានខ្នះខ្នែង ខឹងច្រើនសំដែងឲ្យគេឃើញបាន ។
ហេតុធម៌ទាំងនោះមិនជាកល្យាណ នាំឲ្យខកខានខាតខូចប្រយោជន៍
មានជាប្រធានតិចច្រើនដោយហោច នាំបង់ប្រយោជន៍ហើយឲ្យវិនាស ។

**ឥតិ ហេតំ វិជានាម តតិយោ សោ បរាភវោ**
**ចតុត្ថំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនោះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី ៣ ទាប់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឲ្យទាន
វិនាសទី ៤ អ្វីជាប្រធាន នាំឲ្យសត្វមានសេចក្តីវិនាស ។

**យោ មាតរំ វា បិតរំ វា ជិណ្ណកំ គតយោព្វនំ**
**បហុសន្តោ ន ភរតិ តំ បរាភវតោ មុខំ**

នរជនណាមានទ្រព្យធនធាន ហើយខ្លួនមិនបានចិញ្ចឹមរក្សា
មាតាបីតាដែលចាស់ជរា ហេតុនោះទៅជានាំឲ្យវិនាស ។

**ឥតិ ហេតំ វិជានាម ចតុត្ថោ សោ បរាភវោ**
**បញ្ចមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង    វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ    វិនាសនោះឈ្មោះទី ៤ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត    សូមទ្រង់និមន្តសំដែងឲ្យទាន
វិនាសទី ៥ អ្វីជាប្រធាន    នាំសត្វឲ្យបានសេចក្តីវិនាស ។

**យោ សមណំ ព្រាហ្មណំ វា អញ្ញំ វាបិ វនិព្វកំ**
**មុសាវាទេន វញ្ចេតិ តំ បរាភវតោ មុខំ**

ជនបញ្ឆោតព្រាហ្មណ៍ឬពួកសមណៈ    ពួកស្មូមឬអ្នកដទៃ ៗ
ដោយមុសាវាទឃ្លាតពាក្យប្រពៃ    នោះជាប្រធាននៃសេចក្តីវិនាស ។

**ឥតិ ហេតំ វិជានាម បញ្ចមោ សោ បរាភវោ**
**ឆដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង    វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ    វិនាសនោះឈ្មោះទី ៥ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត    សូមទ្រង់និមន្តសំដែងឲ្យទាន
វិនាសទី ៦ អ្វីជាប្រធាន    នាំសត្វឲ្យបានសេចក្តីវិនាស ។

**បហុតវិត្តោ បុរិសោ សហិរញ្ញោ សភោជនោ**
**ឯកោ ភុញ្ជតិ សាទូនិ តំ បរាភវតោ មុខំ**

បុរសអ្នកមានទ្រព្យធនធានច្រើន    មាសប្រាក់ចំរើននឹងគ្រឿងអាហារ
លបលាក់របស់ដែលឆ្ងាញ់ពិសា    ស៊ីម្នាក់ឯងជាប្រធានវិនាស ។

**ឥតិ ហេតំ វិជានាម ឆដ្ឋមោ សោ បរាភវោ**
**សត្តមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង   វិនាសនោះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ   វិនាសនោះឈ្មោះទី ៦ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត   សូមទ្រង់និមន្តសំដែងឲ្យទាន
វិនាសទី ៧ អ្វីជាប្រធាន   នាំសត្វឲ្យមានសេចក្តីវិនាស ។

**ជាតិត្ថទ្ធោ ធនត្ថទ្ធោ   គោត្តត្ថទ្ធោ ច យោ នរោ**
**សញ្ញាតឹ អតិមញ្ញេតិ   ត បរាភវតោ   មុខំ ។**

អ្នកដែលប្រកាន់ជាតិទ្រព្យត្រកូល   ហើយមិនប្រមូលសាច់ញាតិសន្តាន
មើលងាយញាតិខ្លួនដោយអាងខ្លួនមាន   នេះជាប្រធានសេចក្តីវិនាស ។

**ឥតិហេតំ វិជានាម   សត្តមោ សោ បរាភវោ**
**អដ្ឋមំ ភគវា ព្រូហិ   កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង   វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ   វិនាសនោះឈ្មោះទី ៧ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត   សូមទ្រង់និមន្តសំដែងឲ្យទាន
វិនាសទី ៨ អ្វីជាប្រធាន   នាំសត្វឲ្យមានសេចក្តីវិនាស ។

**ឥត្ថីធុត្តោ សុរាធុត្តោ   អក្ខធុត្តោ ច យោ នរោ**
**លទ្ធំ លទ្ធំ វិនាសេតិ   តំ បរាភវតោ   មុខំ ។**

ជនអ្នកប្រព្រឹត្តល្បែងពាប្រការ   ល្បែងស្រីល្បែងស្រាល្បែងភ្នាល់ទាំងឡាយ
ធ្វើទ្រព្យខ្លួនមានឲ្យអន្តរាយ   ការល្បែងទាំងឡាយនោះនាំវិនាស ។

**ឥតិហេតំ វិជានាម   អដ្ឋមោ សោ បរាភវោ**
**នវមំ ភគវា ព្រូហិ   កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង   វិនាសនោះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ   វិនាសនោះឈ្មោះទី ៨ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត   សូមទ្រង់និមន្តសំដែងឲ្យទាន
វិនាសទី ៩ អ្វីជាប្រធាន   នាំសត្វឲ្យមានសេចក្តីវិនាស ។

**សេហិ ទារេហិ អសន្តុដ្ឋោ វេសិយាសុ បទុស្សតិ**
**ទុស្សតិ បរទារេសុ តំ បរាភវតោ មុខំ ។**

ប្រុសមិនត្រេកអរនិងប្រពន្ធខ្លួន   ហើយទៅជាប់ជួននឹងស្រីពេស្យា
ទ្រុស្តនឹងប្រពន្ធកូនជននានា   ហេតុនោះទៅជានាំឲ្យវិនាស ។

**ឥតិហេតំ វិជានាម នវមោ សោ បរាភវោ**
**ទសមំ ភគវា ព្រូហិ កិំ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង   វិនាសនោះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ   វិនាសនោះឈ្មោះទី ៩ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត   សូមទ្រង់និមន្តសំដែងឲ្យទាន
វិនាសទី ១០ អ្វីជាប្រធាន   នាំសត្វឲ្យមានសេចក្តីវិនាស ។

**អតិត យោព្វនោ បោសោ អានេតិ តិម្ពរុត្ថនិំ**
**តស្សា ឥស្សា ន សុបតិ តំ បរាភវតោ មុខំ ។**

បុរសមានវ័យដែលចាស់ហួសពេក   ហើយមានតម្រេកដោយក្តីតណ្ហា
នាំយកស្រីក្មេងមកធ្វើភរិយា   ហេតុនោះទៅជានាំឲ្យវិនាស ។

**ឥតិហេតំ វិជានាម ទសមោ សោ បរាភវោ**
**ឯកាទសមំ ភគវា ព្រូហិ កិំ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី ១០ ទាន់ហន ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំស្តែងឲ្យទាន
វិនាសទី ១១ អ្វីជាប្រធាន នាំសត្វឲ្យមានសេចក្តីវិនាស ។

**ឥត្ថិំ សោណ្ឌឹ វិកិរណឹ បុរិសំ វាបិ តាទិសំ**

**ឥស្សរិយស្មិំ ឋបេតិ តំ បរាភវតោ មុខំ ។**

បុរសតាំងស្រីអ្នកលេងខ្ជះខ្ជាយ ឬស្រីទាំងឡាយតាំងបុរសនោះដែល
ជាអ្នកលេងខ្ជះខ្ជាយដូច្នោះ អំពើទាំងនោះនាំឲ្យវិនាស ។

**ឥតិ ហេតំ វិជានាម ឯកាទសមោ សោ បរាភវោ**

**ទ្វាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី ១១ ទាន់ហន ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឲ្យទាន
វិនាសទី១២ អ្វីជាប្រធាន នាំសត្វឲ្យមានសេចក្តីវិនាស ។

**អប្បភោគោ មហាតណ្ហោ ខត្តិយេ ជាយតេ កុលេ**

**សោ ច រជ្ជំ បត្ថយតិ តំ បរាភវតោ មុខំ ។**

ជនណាកើតក្នុងត្រកូលក្សត្រ អ្នកខ្សត់សម្បត្តិហើយប្រាថ្នាធំ
ចង់បានជាស្តេចសោយរាជ្យស្តុកស្តម្ភ ហេតុនោះនឹងនាំឲ្យដល់វិនាស ។

**ឯតេ បរាភវេ លោកេ បណ្ឌិតោ សមវេក្ខិយ**

**អរិយោ ទស្សនសម្បន្នោ ស លោកំ ភជតេ សិវំ ។**

ជនជាបណ្ឌិតគំនិតប្រសើរ បានឃើញដំណើរនៃហេតុវិនាស
ដល់សត្វក្នុងលោកសន្និវាស គេចពីវិនាសគប់រកចំរើន ។

( បរាភវសុត្តំ និដ្ឋិតំ )

# ពុទ្ធជយមង្គលគាថា

ប្រែពាក្យជាខេមរភាសា

១- ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ
គ្រីមេខលំ ឧទិតឃោរសសេនមារំ
ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិនពិនលោកា ផ្ចាញ់ក្រុងមារចិត្តមោហន្ធ និម្មិតដៃមួយពាន់ កាន់សស្ត្រាវុធនានា ។ ជិះគ្រីមេខលជាតិ កោញ្ជរទន្តរពសុធា ព្រមដោយមារសេនា ពន្លឹកលន់កងស័ព្ទស៊ាន ។ ដោយធម្មពិធី ទានបារមីជាប្រធាន ក្រុងមារផ្ចាញ់ទ្រង់ញាណ ប្រណម្យកាយថ្វាយវន្ទា ។ រីជយមង្គចូរមានដល់អ្នករាល់គ្នា ដោយតេជៈជយា ព្រះឈ្នះមារគ្រានោះហោង ។

២- មារាតិរេកមភិយុជ្ឈិតសព្វរត្តិំ
ឃោរម្បនាឡវកមក្ខមថទ្ធយក្ខំ
ខន្តី សុទន្តវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិននាយកៈ ផ្ចាញ់អាឡវយក្ខឃោឃៅ រឹងរូសមិនតាំងនៅ ក្នុងខន្តី

គុណសត្យា ។ រហូតអស់រាត្រី ព្រះជិនស្រីទ្រង់យុទ្ធនា ក្រៃលែងក្រុងមារា ក្នុងបឋមសម្ពោធិ ។ ដោយព្រះពិធីញាណ ទ្រង់ទូន្មានដោយខន្តី ញុំាងចិត្តអសុរី ឲ្យបង់ព្យុះចុះវន្ទា ។ រីជយមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជៈជយា ព្រះឈ្នះអាឡវកយក្សហោង ។

៣- នាឡាគិរឹ គជវរំ អតិមត្តភូតំ
ទាវគ្គិចក្កមសនីវ សុទារុណន្តំ
មេត្តម្ពុសេកវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនជិនស្រី ផ្ចាញ់ដំរីឈ្មោះនាឡា- គិរីវរគជា ដ៏ហានក្លាចុះប្រេងព្រៃផ្សៃ ។ សាហាវឆាវឆេះក្រៃ ដូចភ្លើងព្រៃឆេះកំទេច មុតដូចចក្រក្រុតពេជ្យ ខ្លាំងដូចកម្ទអសនី ។ ដោយព្រះពិធីស្រប់ ស្រោចទឹកអប់គឺបារមី មេត្តាព្រះជិនស្រី ញុំាងដំរីឲ្យជ្រះថ្លា ។ រីជយមង្គល ចូរមានអ្នករាល់គ្នា ដោយតេជៈជយា ព្រះឈ្នះនាឡាគិរី ។

៤- ឧក្ខិត្តខគ្គមតិហត្ថសុទារុណន្តំ
ធាវន្តិ យោជនបថង្គុលិមាលវន្តំ
ឥទ្ធីភិសង្ខតមនោ ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនលោកត្រៃ មានព្រះទ័យធ្វើបាដិហារ្យ ផ្ចាញ់ចោរអង្គុលមាល៍ មានកម្រងគឺម្រាមដៃ នៃមនុស្សដែលគាត់កាត់ មកដោត់ចាក់ជាមាល័យ អង់អាចកំណាចក្រៃ ដ៏មានដៃស្ទាត់ប្រហារ ។ កាន់ដាវងារគ្រវី

ដេញព្រះមុនីសាស្តាចារ្យ ចម្ងាយផ្លូវកន្តារ កណ្តាលព្រៃបីយោជនា រីជយមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជៈជយា ព្រះឈ្មោះអង្គុលិមាល៍

**៥- កត្វាន កដ្ឋមុទរំ ឥវ គព្ភិនិយា**

**ចិញ្ចាយ ទុដ្ឋវចនំ ជនកាយមជ្ឈេ**

**សន្តេន សោមវិធិនា ជិតវា មុនិន្ទោ**

**តន្តេជសា ភវតុ តេ ជយមង្គលានិ**

ព្រះមុនិន្ទមានព្រះភាគ ផ្ចាញ់ទ្រុស្តពាក្យនាងចិញ្ចា អំពើធ្វើដូចជា ស្រីមានគភ៌ចាស់ចើលពោះ ។ យកឈើធ្វើជាកូន ព័ទ្ធពោះខ្លួនពោលទ្រគោះ ព្រះពុទ្ធឈ្មោះកាលនោះ ដោយសមាចាពិធី ។ រំងាប់ពាក្យចណ្ឌាល នាកណ្តាលជនប្រុសស្រី ចិញ្ចាចាញ់បារមី គឺសច្ចៈពាក្យសត្យា ។ រីជយមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជៈជយា ព្រះសាស្តាឈ្នះចិញ្ចា ។

**៦- សច្ចំ វិហាយមតិសច្ចកវាទកេតុំ**

**វាទាភិរោបិតមនំ អតិអន្ធភូតំ**

**បញ្ញាបទីបជលិតោ ជិតវា មុនិន្ទោ**

**តន្តេជសា ភវតុ តេ ជយមង្គលានិ**

ព្រះមុនិន្ទពិនអ្នកប្រាជ្ញ រុងរឿងស្វាចដោយបញ្ញា ផ្ចាញ់សច្ចកជា និគ្រន្ថក្រៅពុទ្ធវិន័យ ។ អធ្យាស្រ័យលះបង់ ពាក្យសត្យត្រង់តាមគាប់ចៃ សរសើរខ្លួនឯងក្រៃ លើកកំពស់ដូចដងទង់ ។ បង្កើតមូរងងឹត ដោយពោលផតពាក្យទៀងត្រង់ ព្រះទ្រង់កម្ចាត់បង់ ដោយប្រទីបគឺបញ្ញា រីជយមង្គល ចូរមានដល់អ្នករាល់គ្នា ដេយតេជៈជយា ព្រះឈ្មះសច្ចកៈនិគ្រន្ថ ។

ដេញព្រះមុនីសាស្តាចារ្យ ចម្ងាយផ្លូវកន្តារ កណ្តាលព្រៃបីយោជនា វីជយមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជៈជយា ព្រះឈ្មោះអង្គុលិមាល៍

**៥- កត្វាន កដ្ឋមុទរំ ឥវ គព្ភិនិយា**

**ចិញ្ចាយ ទុដ្ឋវចនំ ជនកាយមជ្ឈេ**

**សន្តេន សោមវិធិនា ជិតវា មុនិន្ទោ**

**តន្តេជសា ភវតុ តេ ជយមង្គលានិ**

ព្រះមុនិន្ទមានព្រះភាគ ផ្ចាញ់ទ្រុស្តពាក្យនាងចិញ្ចា អំពើធ្វើដូចជា ស្រីមានគភ៌ចាស់ចើលពោះ ។ យកឈើធ្វើជាកូន ព័ទ្ធពោះខ្លួនពោលទ្រគោះ ព្រះពុទ្ធឈ្មោះកាលនោះ ដោយសមាចាពិធី ។ រំងាប់ពាក្យចណ្ឌាល នាកណ្តាលជនប្រុសស្រី ចិញ្ចាចាញ់បារមី គឺសច្ចៈពាក្យសត្យា ។ វីជយមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជៈជយា ព្រះសាស្តាឈ្នះចិញ្ចា ។

**៦- សច្ចំ វិហាយមតិសច្ចកវាទកេតុំ**

**វាទាភិរោបិតមនំ អតិអន្ធភូតំ**

**បញ្ញាបទីបជលិតោ ជិតវា មុនិន្ទោ**

**តន្តេជសា ភវតុ តេ ជយមង្គលានិ**

ព្រះមុនិន្ទពិនអ្នកប្រាជ្ញ រុងរឿងស្វាចដោយបញ្ញា ផ្ចាញ់សច្ចកជា និគ្រន្ថ-ក្រៅពុទ្ធវិន័យ ។ អធ្យាស្រ័យលះបង់ ពាក្យសត្យត្រង់តាមគាប់ចៃ សរសើរខ្លួនឯងក្រៃ លើកកំពស់ដូចដងទង់ ។ បង្កើតមូរងងឹត ដោយពោលឥតពាក្យទៀងត្រង់ ព្រះទ្រង់កម្ចាត់បង់ ដោយប្រទីបគឺបញ្ញា វីជយមង្គល ចូរមានដល់អ្នករាល់គ្នា ដេយតេជៈជយា ព្រះឈ្មោះសច្ចកៈនិគ្រន្ថ ។

៧- នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធឹ
បុត្តេន ថេរភុជគេន ទមាបយន្តោ
ឥទ្ធូបទេសវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទ្ទពិនទ្រង់ញាណ ញុំាងមេគ្គល្លានមានអំណាច ឲ្យប្លែងជានាគរាជ ទៅទូន្មានព្យុះភុជង្គ ។ ឈ្មោះនន្ទោបនន្ទ ចិត្តមោហន្ធរឿងឫទ្ធិរុង្គ ទិដ្ឋិកាចទ្រនង់ ទ្រង់ផ្ចាញ់ដោយពិធីឈាន ។ គឺឲ្យឧបទេស ឫទ្ធិវិសេសដល់ មោគ្គល្លាន ឫទ្ធិនាគអន្តរធាន ខិនចុះចាញ់ព្រះចេស្តា ។ រីជយមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ព្រះភគវាឈ្នះនាគហោង ។

៨- ទុគ្គាហទិដ្ឋិភុជគេន សុទដ្ឋហត្ថំ
ព្រហ្មំ វិសុទ្ធិជុតិមិទ្ធិពកាភិធានំ
ញាណាគទេន វិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ម្រុនិន្ទពិនគោតម ផ្ចាញ់មហាព្រហ្មឈ្មោះពកា សម្គាល់ថាអាត្មារុងរឿង ដោយគុណបរិសុទ្ធិ ។ ដៃកាន់អាសិរ្ពិស គឺចិត្តទ្រឹស្ដដ៏មោះមុត កាន់ខុស ផ្លូវសម្ពុទ្ធ មិនលើកលាកលះបង់ប្រាណ ។ ទ្រង់ឈ្នះដោយពិធី ឱសថ-វិសេសសម្រាន្ត ផ្សំត្រូវគាប់សន្តាន គឺព្រះញាណប្រោសទេសនា ។ រីជយ មង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ឈ្នះព្រហ្មាឥតមានហ្មង។

ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា
យោ វាចនោ ទិនទិនេ សរតេ មតន្ទី

**ហិត្វាន នេកវិវិធានិ ចុបទ្ទវានិ**

**សោត្ថឹ សុខំ អធិគមេយ្យ នរោ សបញ្ញោ ។**

**យោ នរោ** ជនឯណា កបបញ្ញាប្រាសក្តីខ្ជិល ឧស្សាហ៍សាងទានសីល សូត្ររំលឹកព្រះធម៌ថ្ងៃ ។ គាថាប្រាំបីបទ នេះកំណត់ឈ្មោះពុទ្ធជ័យ ខំសូត្រសព្វ ៗ ថ្ងៃ កើតមង្គលជានិរន្តរ៍ ។ **សោ នរោ** រីជននោះ បានរំដោះរោគអាសន្ន ឧបទ្រពអនេកលន់ មានប្រការផ្សេងៗផង ។ នឹងដល់ធម៌ក្សេមក្សាន្ត គឺនិព្វានសុខកន្លង លែងទុក្ខទាំង ៤ កង ដោយពុទ្ធជ័យមង្គលនេះ ។

( ចប់ពុទ្ធជយមង្គលគាថា )

# នមស្សការព្រះពុទ្ធប្រាន

ប្រែជាកាព្យ

**វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ**

**តិលោកកេតុំ តិភវេកនាថំ**

**យោ លោកសេដ្ឋោ សកលំ កិលេសំ**

**ឆេត្វាន ពោធេសិ ជនំ អនន្តំ ។**

ព្រះសព្វញ្ញូពុទ្ធ វិសេសផុតត្រៃលោកា
គ្មានមនុស្សឬទេវតា ព្រហ្មមារណាប្រដូចបាន ។
កំចាត់នូវកិលេស គ្មានឲ្យសេសនៅសល់ខាន
ញុំាងជនទាំងប៉ុន្មាន ជាអនន្តឲ្យត្រាស់ដឹង ។

ខ្ញុំសូមថ្វាយបង្គំ នូវព្រះបរមជាទីពឹង
ព្រះអង្គឆ្លងផុតស្ទឹង បានដល់ច្រាំងនៃភពហើយ ។
ព្រះអង្គជាទង់ជ័យ ធំត្រៃលៃបង្ហាញត្រើយ
តែមួយព្រះអង្គហើយ ជាទីពឹងក្នុងត្រៃភព ។
មារព្រហ្មទាំងទេពតា នឹងមនុស្សាតែងគោរព
ចូលជ្រកនៅក្រោមម្លប់ ពោធិញាណបានសុខា ។

**យំ នម្មទាយ នទិយា បុលិនេ ច តីរេ**
**យំ សច្ចពន្ធគិរិកេ សុមនាចលគ្គេ**
**យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ**
**តំ បាទលញ្ឆនមហំ សិរសា នមាមិ ។**

សូមថ្វាយបង្គំ ទសករប្រណម្យ ឆ្ពោះត្រង់ស្ថានព្រះបាទា
ដែលព្រះមានជោគ ទ្រង់ព្រះមេត្តា ជាន់ទុកឲ្យជាស្ពានថ្លៃ ។
បាទមួយនៅនា ស្ទឹងនម្មទា ត្រង់ឆ្នេរខ្សាច់ប្រសើរក្រៃ
បាទមួយទ្រង់ជាន់ ទុកនៅឰ- ដ៏ភ្នំគិរីសច្ចព័ន្ធ ។
បាទមួយនៅភ្នំ សុមនកូដ រហូតកំពូលដ៏សោភ័ណ
ព្រះបាទមួយទៀត ព្រះអង្គទ្រង់ជាន់ ទុកនៅនាយោនកបុរី ។
ខ្ញុំសូមបន្ទន់ កាយវាចា នឹងចិត្តជ្រះថ្លាឱនសិរសី
បង្គំព្រះបាទ ព្រះជិនស្រី សូមសុខសួស្តីគ្រប់វេលា ។

**សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ**
**យោនកបុរេ នម្មទាយ នទិយា**

**បញ្ចដ្ឋានវរំ ឋានំ អហំ វន្ទាមិ ទូរតោ ។**

សូមនមស្ការអំពីចម្ងាយ នូវឋានទាំងឡាយដែលមានព្រះបាទ
ទាំង ៥ កន្លែងដែលព្រះមុនីនាថ ទ្រង់ឈានព្រះបាទលើកំពូលភ្នំ ។
សុវណ្ណមាលិកមួយនោះជាធំ មួយនៅលើភ្នំសុវណ្ណបពិត
មួយនៅលើភ្នំសុមនកូដប្រាកដ មួយនៅរាជរដ្ឋយោនកបុរី ។
មួយនៅក្បែរស្ទឹងនម្មទាជលធី ទាំងប្រាំនាទីដែលទ្រង់ប្រទាន
ទុកឲ្យសព្វសត្វប្រតិបត្តិជាស្ថាន ដោយព្រះទ្រង់ញាណប្រទានទុកឲ្យ ។

## បច្ឆិមពុទ្ធវចន

**យោ វោ អានន្ទ មយា ធម្មោ**
**ច វិនយោ ច ទេសិតោ បញ្ញត្តោ**

ម្នាលអានន្ទ សភាវៈឯណា គឺព្រះធម៌ក្តី ព្រះវិន័យក្តី ដែលតថាគតបានសំដែងហើយ បានបញ្ញត្តហើយដល់អ្នកទាំងឡាយ ។

**សោ វោ មមច្ចយេន សត្ថា**

សភាវៈគឺព្រះធម៌ នឹងព្រះវិន័យនោះ លុះអំណើះតតអំពីតថាគតទៅហើយ នឹងបានជាគ្រូប្រៀនប្រដៅនូវអ្នកទាំងឡាយ ។

**អហំ ឯកកោវ បរិនិព្វាយិស្សាមិ**

តថាគតជាព្រះពុទ្ធមួយអង្គឯងពិត នឹងបរិនិព្វានទៅ ។

**អហញ្ច បនិទានិ ឯកកោវ ឥទានិ អនុសាសេមិ**

តែថាឥឡូវនេះ តថាគតជាព្រះពុទ្ធមួយអង្គឯងពិត តែងទូន្មានប្រៀន-

ប្រដៅនូវអ្នកទាំងឡាយ ។

**មយិ បរិនិព្វុតេ**

កាលបើតថាគតបរិនិព្វានទៅហើយ ។

**ឥមានិ ចតុរាសីតិធម្មក្ខន្ធសហស្សានិ**

**តុម្ហេ និចនិស្សន្តិ អនុសាសិស្សន្តិ**

ព្រះធម្មក្ខន្ធ ប្រាំបីហ្មឺនបួនពាន់នេះ នឹងទូន្មានប្រៀនប្រដៅនូវអ្នកទាំងឡាយជាខាងក្រោយ ។

**យោ ខោ អានន្ទ ភិក្ខុ វា ភិក្ខុនី វា**

**ឧបាសកោ វា ឧបាសិកា វា ធម្មានុធម្មប្បដិបន្នោ**

**វិហរតិ សាមីចិ បដិបន្នោ អនុធម្មចារី**

ម្នាលអានន្ទ បុគ្គលឯណាមួយ គឺភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិធម៌វិន័យតាមសមគួរដល់ធម៌វិន័យ ជាអ្នកប្រតិបត្តិដោយសេចក្តីគោរពកោតក្រែងដល់ធម៌វិន័យ ប្រតិបត្តិតាមធម៌វិន័យជាប្រក្រតី ។

**សោ តថាគតំ សក្ការោតិ គរុករោតិ មានេតិ**

**បូជេតិ បរមាយ បូជាយ បដិបត្តិបូជាយ**

បុគ្គលទាំងអស់នោះបានឈ្មោះថាធ្វើសក្ការៈនឹងតថាគត ធ្វើនូវសេចក្តីគោរពតថាគត រាប់អាននូវតថាគត បូជានូវតថាគត ដោយបដិបត្តិបូជា ជាបូជាយ៉ាងក្រៃលែង ។

**ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ**
**ភិក្ខវេ ខយវយធម្មា សង្ខារា អប្បមាទេន**
**សម្បាទេថាតិ ឥទម្បច្ឆិមពុទ្ធវចនំ**

ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះតថាគត នឹងផ្តាំនូវអ្នកទាំងឡាយឲ្យបាននឹងគ្រប់គ្នា នៃភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មានកិរិយាអស់ទៅ នឹងសាបសូន្យទៅជាធម្មតា ។ អ្នករាល់គ្នា ចូរញ៉ាំងប្រយោជន៍ឲ្យដល់ព្រមដោយអប្បមាទៈ គឺការមិនបណ្តែតបណ្តោយក្នុងធម៌វិន័យ ពាក្យប្រៀនប្រដៅមានប្រមាណប៉ុណ្ណេះជាដើមនេះ ឈ្មោះថាបច្ឆិមពុទ្ធវចនៈ ជាពាក្យផ្តាំពៅបំផុតរបស់ព្រះពុទ្ធជាម្ចាស់នៃយើង ។

**ឧភិន្នមន្តរេ យំ វុត្តំ ឯតំ មជ្ឈិមពុទ្ធវចនំ ។**

ពាក្យប្រដៅឯណា ដែលទ្រង់ត្រាស់ពោលជាចន្លោះនៃបឋម-ពុទ្ធវចបៈ នឹងបច្ឆិមពុទ្ធវចនៈ ទាំងពីរនេះពាក្យប្រដៅនោះ ឈ្មោះថាមជ្ឈិមពុទ្ធវចនៈ គឺពាក្យប្រដៅជាកណ្តាល របស់ព្រះពុទ្ធជាបរមគ្រូនៃយើង ។

( ចប់បច្ឆិមពុទ្ធវចនៈ )

# ធម៌សុខោ

**សុខោ ពុទ្ធានមុប្បាទោ** កិរិយាកើតឡើងនៃព្រះពុទ្ធទាំងឡាយ ជាទីនាំមកនូវសេចក្តីសុខ ។

**សុខា សទ្ធម្មទេសនា** កិរិយាសំដែងនូវព្រះសទ្ធម្ម គឺព្រះបរិយត្តិធម៌ នឹងព្រះនព្វលោកុត្តរធម៌ ជាទីនាំមកនូវសេចក្តីសុខ ។

**សុខា សង្ឃស្ស សាមគ្គី** សេចក្តីព្រមព្រៀងគ្នានៃព្រះសង្ឃ ជាទីនាំមកនូវសេចក្តីសុខ ។

**សមគ្គានំ តបោ សុខោ** តបៈគុណនៃព្រះសង្ឃទាំងឡាយ អ្នកព្រមព្រៀងគ្នា ជាទីនាំមកនូវសេចក្តីសុខ ។

**ទិវា តបតិ អាទិច្ចោ** ព្រះអាទិត្យរុងរឿងបានតែក្នុងវេលាថ្ងៃ

**រត្តិមាភាតិ ចន្ទិមា** ព្រះចន្ទរុងរឿងបានតែក្នុងវេលាយប់ ។

**សន្នទ្ធោ ខត្តិយោ តបតិ** ព្រះមហាក្សត្រលុះតែទ្រង់គ្រឿងប្រដាប់សម្រាប់រាជ្យ ទើបរុងរឿងបាន ។

**ឈាយី តបតិ ព្រាហ្មណោ** ព្រាហ្មណ៍លុះតែចំរើននូវឈាន ទើបរុងរឿងបាន ។

**អថ សព្វមហោរត្តឹ ពុទ្ធោ តបតិ តេជសា** ឯព្រះពុទ្ធជាម្ចាស់ ទ្រង់រុងរឿងដោយតេជៈទាំងថ្ងៃទាំងយប់ ។

**ឯតេន សច្ចវជ្ជេន សុវត្ថិ ហោតុ សព្វទា** សេចក្តីសុខសួស្តី សូមកើតមានក្នុងកាលទាំងពួង ដោយកិរិយាពោលនូវពាក្យសច្ចនេះ ។

**ហិរិឱត្តប្បសម្បន្នា សុក្កធម្មសមាហិតា**

**សន្តោ សប្បុរិសា លោកេ ទេវ ធម្មាតិ វុច្ចរេ** សប្បុរសទាំងឡាយ មានចិត្តរម្ងាប់ប្រកបព្រមហើយដោយ ហិរិ នឹង ឱត្តប្បៈ (ថែមទាំង) មានចិត្តចុះស៊ប់ចំពោះធម៌មានពណ៌ស (សុចរិតធម៌

អ្នកប្រាជ្ញទាំងឡាយលោកឲ្យនាមថា អ្នកមានទេវធម៌ក្នុងលោក ។

**សរណាគមនវត្ថុគាថា**

**ពហុំ វេ សរណំ យន្តិ បព្វតានិ វនានិ ច**

**អារាមរុក្ខចេត្យានិ មនុស្សានិ ភយតជ្ជិតា**

មនុស្សទាំងឡាយមានចំនួនច្រើន កាលដែលភ័យគ្របសង្កត់ហើយតែងយកភ្នំទាំងឡាយខ្លះ ព្រៃទាំងឡាយខ្លះ អារាមនឹងដើមឈើដែលជាចេតិយទាំងឡាយខ្លះ ជាទីពឹង ,

ប្រែជាពាក្យកាព្យ

មនុស្សទាំងឡាយជាច្រេនគ្នា កាលមានគ្រាភ័យអាសន្ន
តែងចូលទៅបន់ស្រន់ ទីពឹងមន្តផងនានា
អ្នកខ្លះពឹងព្រៃភ្នំ ព្រៃតូចធំដែនសីមា
អារាមនឹងរុក្ខា និងចេត្យាមិនមានសល់ ។

**នេតំ ខោ សរណំ ខេមំ នេតំ សរណមុត្តមំ**

**នេតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ**

ទីពឹងនុ៎ះឯងមិនមែនជាទីពឹងដ៏ក្សេម ទីពឹងនុ៎ះមិនមែនជាទីពឹងដ៏ឧត្តម បុគ្គលមិនដែលរួចស្រឡះចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនុ៎ះទេ ។

ប្រែជាកាព្យ

ទីពឹងនោះឯងនែ ព្រោះអាស្រ័យមិនក្សេមក្សាន្ត ទីពឹងនុ៎ះមិនបាន
ឈ្មោះថាទីពឹង**ឧត្តម** ជនណាចូលសម្ងំ ព្រោះអាស្រ័យទីពឹងនុ៎ះ
ជននោះមិនបានសុខ រួចចាកទុក្ខផងទាំងពួង ។

**យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ**
**ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ ទុក្ខំ**
**ទុក្ខសមុប្បាទំ ទុក្ខស្ស អតិក្កមំ អរិយញ្ចដ្ឋង្គិកំ**
**មគ្គំ ទុក្ខូបសមគាមិនំ ,**

បុគ្គលណាមួយបានដល់នូវព្រះពុទ្ធព្រះធម៌នឹងព្រះសង្ឃ ជាទីពឹងទីរលឹក ហើយឃើញនូវអរិយសច្ចទាំង ៤ គឺសេចក្តីទុក្ខ ១, សមុទយជាដែនកើតឡើងព្រមនៃសេចក្តីទុក្ខ ១, និរោធជាទីកន្លងបង់នូវសេចក្តីទុក្ខ ១, មគ្គមានអង្គ ៨ ដ៏ប្រសើរដែលញ៉ាំងសត្វឲ្យដល់នូវព្រះនិព្វាន ជាស្ពានរម្ងាប់បង់នូវសេចក្តីទុក្ខ ១, ដោយប្រាជ្ញាដ៏ត្រូវ ។

(*ប្រែជាកាព្យ*)

លុះតែបុគ្គលណា ចិត្តជ្រះថ្លាចំពោះដល់ ព្រះពុទ្ធព្រះធម៌ផង
ហើយទីពឹងនូវព្រះសង្ឃ ថែមទាំងមានបញ្ញា ពិចារណាតាមគន្លង
សច្ចៈទាំង ៤ កង ឲ្យមត់ហ្មងដោយប្រពៃ ទី ១ គឺទុក្ខសច្ច
ដែលចរត្រាច់តាមហ្វទ័យ ទី ២ សមុទ័យ ញ៉ាំងទុក្ខភ័យឲ្យកកើត
ទី ៣ គឺនិរោធ ដែលរលត់នូវទុក្ខភ័យ ទី ៤ នោះគឺមគ្គ
មានលក្ខណៈអង្គ ៨ ជាផ្លូវព្រះអរិយ៍ ផ្លូវប្រពៃគួរយាត្រា
ផ្លូវនេះជាផ្លូវត្រង់ កាត់តម្រង់ទៅអមតា ។

**ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ**
**ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ**

ទីពឹងនុ៎ះឯងជាទីពឹងដ៏ក្សេម ទីពឹងនុ៎ះជាទីពឹងដ៏ឧត្តម (របស់បុគ្គលនោះ) បុគ្គលរមែងរួចស្រឡះចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនុ៎ះឯង ។

( ពាក្យប្រែកាព្យ )

ទីពឹងនុ៎ះឯងនៃ ព្រោះអាស្រ័យក្សេមឧត្តម ជនណាចូលសម្ងំ អាស្រ័យដោយទីពឹងនុ៎ះ ជននោះនឹងបានសុខ រួចចាកទុក្ខទាំងពួង ។

# ទលិទ្ទសុត្តគាថា

**យស្ស សទ្ធា តថាគតេ អចលា សុបតិដ្ឋិតា**

បុគ្គលឯណាមានសេចក្ដីជឿដ៏កលមាំឥតកំរើក ចំពោះព្រះតថាគត

**សីលញ្ច យស្ស កល្យាណំ អរិយកន្តំ បសំសិតំ**

បុគ្គលឯណាមានសីលដ៏ល្អ ជាទីត្រេកអរនៃព្រះអរិយៈ ដែលព្រះអរិយៈទាំងឡាយលោកសរសើរហើយ,

**សង្ឃេ បសាទោ យស្សត្ថិ ឧជុភូតញ្ច ទស្សនំ**

បុគ្គលឯណា មានសេចក្ដីជ្រះថ្លាចំពោះព្រះសង្ឃផង មានសេចក្ដីយល់ឃើញដ៏ត្រូវត្រង់ផង

**អទលិទ្ទោតិ តំ អាហុ អមោឃន្តស្ស ជីវិតំ**

បណ្ឌិតទាំងឡាយលោកហៅបុគ្គលនោះ ថាមិនមែនជាអ្នកទាល់ក្រឡើយ ជីវិតរបស់បុគ្គលនោះមិនមែនសោះសូន្យឥតប្រយោជន៍ឡើយ,

**តស្មា សទ្ធញ្ច សីលញ្ច បសាទំ ធម្មទស្សនំ**

**អនុយុញ្ជេថ មេធាវី សរំ ពុទ្ធសាសនំ**

ព្រោះហេតុបុគ្គលអ្នកមានប្រាជ្ញា កាលរឭកឃើញនូវសាសនា គឺពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ក៏គួរប្រកបរឿយ ៗ នូវសេចក្ដីជឿផង នូវសីលផង នូវសេចក្ដីជ្រះថ្លាផង នូវកិរិយាឃើញនូវធម៌ផង ។

## គារវសុត្តគាថា

និយាយអំពីការគោរព

**យេ ច អតីតា សម្ពុទ្ធា យេ ច ពុទ្ធា អនាគតា**

**យោ ចេ តរហិ សម្ពុទ្ធោ ពហុន្នំ សោកនាសនោ**

ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់កន្លងហួសទៅហើយក្ដី ព្រះសម្មាសម្ពុទ្ធអង្គឯណា ដែលមិនទាន់បានត្រាស់ក្ដី ព្រះសម្មាសម្ពុទ្ធអង្គឯណា ជាអ្នកញុំាងសេចក្ដីសោករបស់ជនទាំងឡាយច្រើនឲ្យវិនាសទៅ ( មាន ) ក្នុងកាលឥឡូវនេះ,

**សព្វេ សទ្ធម្មគរុនោ** ព្រះសម្មាសម្ពុទ្ធ (ទាំងឡាយនោះ) គ្រប់ព្រះអង្គសុទ្ធតែមានសេចក្ដីគោរពចំពោះព្រះសទ្ធម្ម,

**វិហរឹសុ វិហរតិ ច** ព្រះអង្គគង់នៅរួចទៅហើយក្ដី គង់នៅក្នុងកាលឥឡូវនេះក្ដី,

**អថាបិ វិហរិស្សន្តិ** នឹងគង់នៅតទៅទៀតក្ដី

**ឯសា ពុទ្ធានធម្មតា** កិរិយាបែបនេះ ជាធម្មតារបស់ព្រះពុទ្ធទាំងឡាយ,

**តស្មា ហិ អត្តការមេន មហត្តមភិកង្ខតា**

**សន្ធរម្មា ករុកាតព្វោ សរំ ពុទ្ធានសាសនំ**

ក៏ព្រោះហេតុដូច្នោះ បុគ្គលអ្នកស្រឡាញ់នូវខ្លួន អ្នកប្រាថ្នានូវភារៈជាធំ កាលរឭកឃើញនូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គួរធ្វើនូវសេចក្ដីគោរពចំពោះព្រះសទ្ធម្ម ។

## ធម៌សម្រាប់សូត្រផ្សាយមេត្តាទាំង១០ទិស

**១-សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសខាងកើត កុំបីមានពៀរនិងគ្នា ចូរនៅជាសុខចុះ ។

**២-សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសអគ្នេយ៍ កុំបីមានពៀរនិងគ្នា ចូរនៅជាសុខចុះ ។

**៣-សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសខាងត្បូង កុំបីមានពៀរនិងគ្នា ចូរនៅជាសុខចុះ ។

**៤-សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសនីរតី កុំបីមានពៀរនិងគ្នា ចូរនៅជាសុខចុះ ។

**៥-សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសខាងលិច កុំបីមានពៀរនិងគ្នា ចូរនៅជាសុខចុះ ។

**៦-សព្វេ បច្ចិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសពាយ័ព្យ កុំបីមានពៀរនិងគ្នា ចូរនៅជាសុខចុះ ។

**៧-សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសខាងជើង កុំបីមានពៀរនិងគ្នា ចូរនៅជាសុខចុះ ។

**៨-សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសឦសាន កុំបីមានពៀរនិងគ្នា ចូរនៅជាសុខចុះ ។

**៩-សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសខាងលើ កុំបីមានពៀរនិងគ្នា ចូរនៅជាសុខចុះ ។

**១០-សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសខាងក្រោម កុំបីមានពៀរនិងគ្នា ចូរនៅជាសុខចុះ ។

**សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ**
**អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ**

**អវេរា ហោន្តុ សព្វត្ថិហិ សមិជ្ឈន្តុ សុខំ អត្តានំ បរិហរន្តុ**

សត្វទាំងឡាយទាំងពួង ចូរកុំមានពៀរនិងគ្នា ចូរនៅជាសុខចុះ ចូរកុំមានទុក្ខនិងគ្នា ចូរកុំមានព្យាបាទនិងគ្នា ចូរឲ្យជាអ្នកឥតមានសេចក្តីទុក្ខភ័យ ចូរឲ្យមានអាយុវែង ចូរកុំឲ្យមានរោគ ចូរឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ ចូររក្សាខ្លួនឲ្យបានសេចក្តីសុខចុះ ។

**ទុក្ខប្បត្តា ច និទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ ប្រាណិនោ**

សត្វទាំងឡាយទាំងពួងដែលដល់ហើយ នូវសេចក្តីទុក្ខ សូមឲ្យជាសត្វបាត់សេចក្តីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្តីសោក សូមឲ្យជាសត្វបាត់សេចក្តីសោកទៅ ។

# វិធីធ្វើបុណ្យឧទ្ទិសកុសល

**កំណាព្យពណ៌នាគុណមាតាបិតាគ្រូអាចារ្យ**

អឋាំតាំងស្មារតី ឱនសិរសីថ្វាយបង្គំ ព្រះមេមាតាខ្ញុំ គុណឧត្តុងឧត្តមក្រៃ ។ នូវគុណព្រះបិតា គ្រូអាចារ្យលោកទាំងបី គុណនោះធ្ងន់ពេកក្រៃ រករបស់អ្វីប្រៀបពុំបាន ។ ខ្ញុំក្រអត់ធន់ធាន ធ្វើបុណ្យទានកំដរប្រាណ ខ្ញុំទាល់រកមិនបាន ធ្វើបុណ្យទានសងគុណអ្នក ។ សព្វថ្ងៃមានតែចិត្ត ចិន្តាគិតឃើញជាងជាក់ រលឹកនឹកគុណអ្នក ដែលបង្កើតរូបខ្ញុំមក ។ គ្រូបាអាចារ្យថ្លៃ រៀនបាលីឲ្យប្រែបក បង្ហាត់បង្ហាញមក ឲ្យខ្ញុំចាំចេះក្នុងខ្លួន ។ ឱគុណម្ចាស់ខ្ញុំអើយ

ព្រះសុមេរអើយធំមាំមួន ថយថោកជាបីសួន ប្រៀបនឹងគុណពុំបានទេ ។ ព្រះមេន្ទរឪពុក ស៊ីបញ្ចុកបីបំពេរ បបោសអស់កាយេ ស្រមោចវារលើពិតពុំបាន ។ ខ្ញុំមិនភ្លេចគុណថ្លៃ នឹកសព្វថ្ងៃមិនដែលខាន ព្យាយាមពីប្រុងប្រាណ សូត្របញ្ជូនបុណ្យទៅអ្នក ។ នៅអស់ញាតិកា បងប្អូនណាមានគុណជាក់ ទេវតាឥន្ទ្រព្រហ្មយក្ស ព្រះយមរាជជាសាក្សី ។ ព្រះធម៌ជាពេជ្រញាណ ត្បិតខ្ញុំមានចិត្តស្មោះស្ម័គ្រ រឭកភ្ជាក់ស្មើរមាណ ថ្វាយបង្គំគុណស្មើរណោះ ។ នៅឯអង្គអក្ខរា តេត្តីសាសាមសិបនោះ សាមបីជាចំពោះ ដែលបង្កើតរូបខ្ញុំណា ។ កាយេប្រែថាខ្លួន នោះមានបួនរាល់រូបា កកើតជាកេសា សក់សោតណាកំណត់មាន ។ ឯរោមប្រាំបួនកោដិ ឯសក់សោតប្រាំបួនលាន រាល់គ្នាសុទ្ធសឹងមាន លោកបានទុកកំណត់មក ។ ទោសឯណាដែលខ្ញុំធ្វើ ខុសឆ្គងលើម៉ែពុកពិត ដោយកាវាចាចិត្ត ភ្លេចនឹកគិតធ្វើហួសទៅ ។ សូមម៉ែពុកអនុគ្រោះ ទ្រង់សន្តោសអត់ទោសខ្ញុំ ខុសឆ្គងម៉ែពុកកុំ យកទោសខ្ញុំតទៅទៀត ។ ដើម្បីនឹងសង្គ្រួម រវឹងព្រមមិនឲ្យឃ្លាត សូមជួបម៉ែពុកទៀត រហូតដល់និព្វានហោង ។ ៚

## គាថាសូត្រមេត្តាសូត្រ

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវានាគា មហិទ្ធិកា**
**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ ។**

ទេវតាទាំងឡាយ ស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី

នាគទាំងឡាយមានឫទ្ធានុភាពច្រើនក្តី ចូរអនុមោទនានូវបុណ្យនៃយើងទាំងឡាយ ចូររក្សានូវព្រះពុទ្ធសាសនា (ឲ្យបានសុខចំរើន ) អស់កាលជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភូម្មដ្ឋា ទេវានាគា មហិទ្ធិកា**

**បុញ្ញំ តំ អនុមោទិត្វា ចិរំ រក្ខន្តុ រដ្ឋកេ ។**

ទេវតាទាំងឡាយ ស្ថិតនៅឰដ៏អាកាសក្តី ស្ថិនៅលើផែនដីក្តី នាគទាំងឡាយមានឫទ្ធានុភាពច្រើនក្តី ចូរអនុមោទនានូវបុណ្យនៃយើងទាំងឡាយ ចូររក្សានូវមហាជនក្នុងរដ្ឋទាំងឡាយ (ឲ្យបានសុខចំរើន) អស់កាលជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភូម្មដ្ឋា ទេវានាគា មហិទ្ធិកា**

**បុញ្ញំ តំ អនុមោទិត្វា ចិរំ រក្ខន្តុ ញាតយោ ។**

ទេវតាទាំងឡាយ ស្ថិតនៅឰដ៏អាកាសក្តី ស្ថិនៅលើផែនដីក្តី នាគទាំងឡាយមានឫទ្ធានុភាពច្រើនក្តី ចូរអនុមោទនានូវបុណ្យនៃយើងទាំងឡាយ ចូររក្សានូវញាតិទាំងឡាយ (ឲ្យបានសុខចំរើន) អស់កាលជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភូម្មដ្ឋា ទេវានាគា មហិទ្ធិកា**

**បុញ្ញំ តំ អនុមោទិត្វា ចិរំ រក្ខន្តុ ប្រាណិនោ ។**

ទេវតាទាំងឡាយ ស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយមានឫទ្ធានុភាពច្រើនក្តី ចូរអនុមោទនានូវបុណ្យនៃយើងទាំងឡាយ

ឡាយ ចូររក្សានូវសត្វទាំងឡាយ (ឲ្យបានសុខចំរើន) អស់កាលជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវានាគា មហិទ្ធិកា**

**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ នោ សទា ។**

ទេវតាទាំងឡាយ ស្ថិតនៅឯអាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយមានឫទ្ធានុភាពច្រើនក្តី ចូរអនុមោទនានូវបុណ្យនៃយើងទាំងឡាយ ចូររក្សានូវយើងទាំងឡាយ (ឲ្យបានសុខចំរើន) សព្វ ៗ កាល អស់កាលជាយូរអង្វែងទៅ ។

## បត្តិទានគាថា

**យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ តា ធម្មទានេន ភវន្តុ បូជិតា សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ ថេរា ច មជ្ឈា នវកា ច ភិក្ខវោ សារាមិកា ទានបតី ឧបាសកា គាមា ច ទេសា និគមា ច ឥស្សរា សប្បាណភូតា សុខិតា ភវន្តុ តេ ជលាពុជា យេ បិ អណ្ឌសម្ភវា សំសេទជាតា អថ វោបបាតិកា និយ្យានិកំ ធម្មវរំ បដិច្ចតេ សព្វេបិ ទុក្ខស្ស ករោន្តុ សង្ខយំ ឋាតុ ចិរំ សតំ ធម្មោ ធម្មធរា ច បុគ្គលា សង្ឃោ ហោតុ សមគ្គោ វ អត្ថាយ ច ហិតាយ ច អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ វុឌ្ឍឹ សម្បាបុណេយ្យាម ធម្មេ អរិយប្បវេទិតេ ។**

ប្រែថា-**យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ** ទេវតាទាំងឡាយឯណាមានប្រក្រតីនៅក្នុងទីវិត្តជាទីនៅសង្ឃ ឮដ៏ខឿនព្រះស្តូប ឮដ៏ខឿនព្រះពោធិព្រឹក្សក្នុងទីនោះ ៗ **តា ធម្មទានេន ភវន្តុ បូជិតា** ទេវតាទាំងឡាយនោះ ជាបុគ្គលគឺយើងទាំងឡាយបូជាហើយ ដោយធម្មទាន **សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ** ចូរធ្វើនូវសួស្តីក្នុងមណ្ឌលនៃវិត្តជាទីនៅនៃសង្ឃនេះ **ថេរា ច មជ្ឈា នវកា ច ភិក្ខវោ** ភិក្ខុទាំងឡាយជាថេរៈក្តី ជាកណ្តាលក្តី ទើបនឹងបួសថ្មីក្តី **សារាមិកា ទានបតី ឧបាសកា** ឧបាសកនឹងឧបាសិកាទាំងឡាយដែលជាម្ចាស់នៃទាន ព្រមទាំងអារាមិកជនគឺញោមវិត្តក្តី **គាមា ច ទេសា និគមា ច ឥស្សរា** ជនទាំងឡាយដែលជាអ្នកស្រុកក្តី ជាអ្នកប្រទេសក្តី ជាអ្នកនិគមក្តី ដែលជាឥស្សរៈជាធំក្តី **សប្បាណភូតា សុខិតា ភវន្តុ តេ** សត្វទាំងឡាយនោះ ៗ ចូរឲ្យបានដល់នូវសេចក្តីសុខ **ជលាពុជា យេបិ ច អណ្ឌសម្ភវា សំសេទជាតា អថ វោបបាតិកា** មួយវិញទៀត សត្វទាំងឡាយឯណាដែលជាជលាពុជៈកំណើតក្តី ដែលជាអណ្ឌជៈកំណើតក្តី ដែលជាសំសេទជៈកំណើតក្តី ដែលជាឧបបាតិកៈកំណើតក្តី **និយ្យានិកំ ធម្មវរំ បដិច្ចតេ សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ** សត្វទាំងឡាយទាំងអស់នោះ កាលបើបានអាស្រ័យនូវធម៌ដ៏ប្រសើរជានិយ្យានិកៈធម៌ហើយ ចូរធ្វើនូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខចុះ **ឋាតុ ចិរំ សតំធម្មោ** សូមឲ្យធម៌របស់សប្បុរសទាំងឡាយស្ថិតនៅអស់កាលយូរអង្វែង **ធម្មធរា ច បុគ្គលា** បុគ្គលអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ ចូរស្ថិត

នូវនៅអស់កាលដ៏យូរអង្វែងទៅ **សង្ឃោ ហោតុ សមគ្គោ ច** សូមព្រះសង្ឃព្រមព្រៀងគ្នា អត្ថាយ ច ហិតាយ ច ដើម្បីសេចក្តីចំរើនផង ដើម្បីសេចក្តីសម្រេចផលប្រយោជន៍ផង **ធម្មោ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ** សូមព្រះសទ្ធម្មរក្សានូវយើងទាំងឡាយ សូមរក្សានូវអ្នកប្រព្រឹត្តធម៌ទាំងឡាយទាំងអស់ផង **វុឌ្ឍិសម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ** សូមឲ្យយើងទាំងឡាយបានដល់នូវសេចក្តីជំរើន ក្នុងធម៌ដែលព្រះអរិយទាំងឡាយលោកសំដែងហើយ ។

## បត្តិទានមង្គលគាថា

**ឥមិនា បុញ្ញកម្មេន ឧបជ្ឈាយា គុណុត្តរា អាចរិយូបការា ច មាតាបិតា បិយា មមំ សុរិយោ ចន្ទិមា រាជា គុណវន្តា នរាបិ ច ព្រហ្ម មារា ច ឥន្ទ្រា ច លោកបាលា ច ទេវតា យមោ មិត្តា មនុស្សា ច មជ្ឈត្តា វេរិកាបិ ច សព្វេ សត្តា សុខី ហោន្តុ បុញ្ញានិ បកតានិ មេ សុខញ្ច តិវិធំ ទេន្តុ ខិប្បំ បាបេថ វោមតំ ។ ឥមិនា បុញ្ញកម្មេន ឥមិនា ឧទ្ទិសេន ច ខិប្បាហំ សុលភេ ចេវ តណ្ហុបាទានឆេទនំ យេ សន្តានេ ហិនា ធម្មា យាវ និព្វានតោ មមំ នស្សន្តុ សព្វទា យេវ យត្ថ ជាតោ ភវេ ភវេ ឧជុចិត្តំ សតិបញ្ញា សល្លេខោ វិរិយម្ហិនា មារា លភន្តុ នោកាសំ កាតុញ្ច វិរិយេសុ មេ ពុទ្ធា ធិបវរោ នាថោ ធម្មោ នាថោ វរុត្តមោ នាថោ បច្ចេកពុទ្ធោ ច សង្ឃោ**

**នាថោត្តរោ មមំ តេ សោត្តមានុភាវេន មារោកាសំ លភន្តុ មា ។**

សេចក្តីប្រែ- **ឥមិនា បុញ្ញកម្មេន** ដោយបុញ្ញកម្មនេះ **ឧបជ្ឈាយា គុណុត្តរា** ឧបជ្ឈាទាំងឡាយ មានគុណដ៏ខ្ពង់ខ្ពស់ក្តី **អាចរិយូបការា ច** អាចារ្យទាំងឡាយ មានឧបការៈក្តី **មាតាបិតា បិយា មមំ** មាតានឹងបីតាជាទីស្រឡាញ់នៃខ្ញុំក្តី **សុរិយោ ចន្ទិមា រាជា** ព្រះអាទិត្យ ព្រះចន្ទ នឹងព្រះរាជាក្តី **គុណវន្តា នរាបិ ច** មួយវិញទៀត ជនទាំងឡាយដែលជាអ្នកមានគុណក្តី **ព្រហ្មមារា ច ឥន្ទ្រា ច** ពួកព្រហ្មក្តី មារក្តី ព្រះឥន្ទ្រទាំងឡាយក្តី **លោកបាលា ច ទេវតា** ទេវតាទាំងឡាយជាអ្នករក្សានូវលោកក្តី **យមោ មិត្តា មនុស្សា ច** យមរាជក្តី ពួកមនុស្សជាទីរាប់អានគ្នាក្តី **មជ្ឈត្តា វេរិកាបិ ច** មួយវិញទៀត សត្វទាំងឡាយដែលមានចិត្តជាឧបេក្ខាក្តី មានពៀរនិងគ្នាក្តី **សព្វេសត្តា សុខ ហោន្តុ** សព្វសត្វទាំងឡាយចូរឲ្យបាននូវសេចក្តីសុខ **បុញ្ញានិ បកតានិ មេ** បុណ្យទាំងឡាយដែលខ្ញុំបានធ្វើហើយ **សុខញ្ច តិវិធំ ទេន្តុ** សូមឲ្យបាននូវសេចក្តីទាំង ៣ ប្រការ (គឺសុខក្នុងមនុស្ស, ទេវតា នឹងព្រះនិព្វាន) **ខិប្បំបាបេថ វោមតំ** អ្នកទាំងឡាយចូរដល់នូវព្រះនិព្វាន ឈ្មោះអមតៈដោយឆាប់រួសរាន់ទាន់ចិត្ត។

**ឥមិនា បុញ្ញកម្មេន** ដោយបុញ្ញកម្មនេះផង **ឥមិនា ឧទ្ទិសេន ច** ដោយពាក្យឧទ្ទិសនេះផង **ខិប្បាហំ សុលភេ ចេវ តណ្ហុបាទានឆេទនំ** ខ្ញុំគប្បីបានដោយងាយនូវការកាត់ផ្តាច់តណ្ហា នឹង ឧបាទានដោយឆាប់រួសរាន់ **យេ សន្តានេ ហីនាធម្មា** ធម៌ទាំងឡាយណាដែលថោកទាបមានក្នុងសន្តាន (នៃខ្ញុំ)

**យាវនិព្វានតោ មមំ នស្សន្តុ សព្វទាយេវ** ធម៌ថោកទាបទាំនោះ ចូរវិនាសទៅ (ចាកសន្តាន) នៃខ្ញុំសព្វ ៗ កាលដរាបដល់ព្រះនិព្វាន **យត្ថ ជាតោ ភវាភវេ** ខ្ញុំកើតហើយក្នុងភពតូចនឹងភពធំណា ៗ **ឧជុចិត្តំ សតិបញ្ញា សល្លេខោ វិរិយម្ហិ ចា** សូមឲ្យជាអ្នកមានចិត្តត្រង់ មានស្មារតីនឹងប្រាជ្ញា ទាំងសូមឲ្យមានចិត្តផ្ទូរផង់ នឹង សេចក្តីព្យាយាមផង (ក្នុងភពនោះ ៗ) **មារា លភន្តុ នោកាសំ កាតុញ្ចវិរិយេសុ មេ** មារទាំងឡាយចូរកុំបាននូវឱកាសដើម្បីធ្វើ (នូវសេចក្តីអន្តរាយ) ក្នុងព្យាយាមទាំងឡាយនៃខ្ញុំ **ពុទ្ធោ ទីបវរោ នាថោ** ព្រះពុទ្ធដូចជាប្រទីបដ៏ប្រសើរ ព្រះអង្គជាទីពឹង (របស់ខ្ញុំ) **ធម្មោ នាថោ វរុត្តមោ** ព្រះធម៌ដ៏ឧត្តមបវរជាទីពឹង (របស់ខ្ញុំ) **នាថោ បច្ចេកពុទ្ធោ ច** ព្រះបច្ចេកពុទ្ធ ក៏ជាទីពឹង (របស់ខ្ញុំ) **សង្ឃោនាថោត្តរោ មមំ** ព្រះសង្ឃជាទីពឹងដ៏ប្រសើររបស់ខ្ញុំ **តេសោត្តមានុភាវេន** ដោយឧត្តមានុភាពនៃព្រះពុទ្ធ ព្រះធម៌ ព្រះបច្ចេកពុទ្ធ នឹងព្រះសង្ឃទាំងឡាយនោះ **មារោ កាសំ លភន្តុមា** មារចូរកុំបាននូវឱកាសឡើយ ។

## ខមាបនគាថា

**យេ កេចិ ខុទ្ទកា បាណា មហន្តាបិ មយា ហតា**
**យេ បាណេតេ បមាទេន កាយវាចាមនេហិ វា**
**បុញ្ញំ មេ អនុមោទន្តុ គណ្ហន្តុ ផលមុត្តមំ វេរិនោ**
**មេ បមុញ្ចន្តុ សព្វទោសំ ខមន្តុ មេ ។**

**យេកេចិ ខុទ្ទកា បាណា មហន្តាបិ មយា** សត្វទាំងឡាយឯណា ជាសត្វតូចក្តី ធំក្តីដែលខ្ញុំសម្លាប់ហើយ **យេបាណេ បមាទេន កាយវាចាមនេហិ វា** ទោះសត្វទាំងឡាយណាពួកខ្លះ (ដែលខ្ញុំបៀតបៀនហើយ) ដោយកាយវាចាចិត្ត ព្រោះសេចក្តីប្រមាទ **បុញ្ញំ មេ អនុមោទន្តុ** (សត្វទាំងនោះ) ចូរអនុមោទនាត្រេចអរចំពោះបុណ្យរបស់ខ្ញុំ **គណ្ហន្តុ ផលមុត្តមំ** ចូរទទួលយកនូវផលដ៏ឧត្តមចុះ **វេរិនោ មេ បមុញ្ចន្តុ** បើ (សត្វទាំងឡាយណា) មានពៀរនឹងគ្នា (សត្វទាំងឡាយ) នោះ ចូររួចរំដោះចាកពៀរនោះទៅ **សព្វទោសំ ខមន្តុ មេ** សូមសត្វទាំងឡាយអត់នូវទោសទាំងពួងដល់ខ្ញុំ ។

## បត្តិទានគាថា

**យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម កាយេន វាចា មនសា តិទសេ សុគតំ កតំ យេ សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា យេ ច តត្ថ នជានន្តិ ទេវា គន្ត្វា និវេទយុំ សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសា** ។

សេចក្តីប្រែ-**យំកិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម** អំពើជាកុសលឯណាមួយដែលខ្ញុំគប្បីធ្វើ **កាយេន វាចា មនសា** ដោយទ្វារទាំងបី

វាចា ចិត្ត **និវេសេ សុកតំ កតំ** អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំឲ្យទៅកើតក្នុងស្ថានត្រៃត្រឹង្សសួគ៌បាន **យេ សត្តា សញ្ញិនោ អត្ថិ** សត្វទាំងឡាយឯណា គឺមនុស្សឬទេវតាឬព្រហ្មដែលជាសត្វមានសញ្ញាក្តី **យេ ច សត្តា អសញ្ញិនោ** សត្វទាំងឡាយឯណាជាអសញ្ញីសត្វ គឺសត្វដែលឥតមានសញ្ញាក្តី **កតំ បុញ្ញ ផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ** សត្វទាំងឡាយទាំងអស់នោះ ចូរឲ្យបាននូវចំណែកផលនៃបុណ្យ ហើយចូរសោយនូវផលនៃបុណ្យ ដែលខ្ញុំបានធ្វើហើយបានឧទ្ទិសផ្សាយឲ្យទៅនេះចុះ **យេសំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា** បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណា បានដឹងច្បាស់ហើយ សត្វទាំងឡាយនោះចូរឲ្យបានសោយ នូវផលនៃបុណ្យដែលខ្ញុំបានឧទ្ទិសឲ្យទៅនោះចុះ **យេ ច តត្ថ នជានន្តិ** ម្យ៉ាងទៀតបណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយឯណាមិនបានដឹងនូវបុណ្យដែលខ្ញុំបានធ្វើហើយនោះ **ទេវា គន្ត្វា និវេទយុំ** សូមទេវតាទាំងឡាយ អញ្ជើញទៅឲ្យដំណឹងដល់សត្វទាំងឡាយនោះឲ្យបានដឹងផងថា ជនឯណោះគេបានធ្វើបុណ្យហើយ គេឧទ្ទិសផ្សាយផលបុណ្យនោះមកដល់អ្នកទាំងឡាយ ៗ ចូរអនុមោទនាត្រេកអរនឹងបុណ្យគេនោះចុះ **សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា** សត្វទាំងឡាយឯណាក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារហើយរស់នៅ **មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសា**

សត្វទាំងឡាយទាំងអស់នោះ ចូរឲ្យបាននូវភោជនជាទីគាប់ចិត្តដែលសម្រេច ដោយបុញ្ញឫទ្ធិ តាមចិត្តខ្ញុំដែលឧទ្ទិសផ្សាយទៅឲ្យនេះចុះ ។

យំកិញ្ចិ ប្រែជាពាក្យកាព្យ

កុសលកម្ម តិចតួចឯណា ដែលចិត្តជ្រះថ្លា ហើយខ្ញុំបានធ្វើ
ដោយកាយវាចា ចិត្តខ្ញុំអើពើ គួរនាំទៅលើ កើតស្ថានត្រៃត្រិង្ស។
សត្វមានសញ្ញា ឯណាបានដឹង បុណ្យដែលខ្ញុំប្រឹង ខំធ្វើនេះក្តី
សូម្បីពួកសត្វ ជាអសញ្ញី ក៏ខ្ញុំគប្បី ចែកបុណ្យនេះឲ្យ ។
ថាបើពួកសត្វ នោះមិនដឹងហើយ ក៏ខ្ញុំសូមឲ្យ ទេវតាមានឫទ្ធិ
អញ្ជើញទៅប្រាប់ ទៅដាស់តឿនចិត្ត ដោយក្តីអាណិត សត្វក្នុងលោកា ។
ឲ្យបានដឹងហើយ ដោយចិត្តមេត្តា ត្រេកអរគ្រប់គ្នា ក្នុងលោកទាំងមូល
សូមមានអាហាររស់នៅដោយស្រួល ដោយបានទទួល ផលបុណ្យនេះហោង

## តេជៈខ្ញុំសាង

តេជៈខ្ញុំសាង សំអិតសំអាង ឱនកាយវាចា
សូមសុខសុភាព រួចពីទុក្ខា ឆ្លងដល់ត្រើយមហា
ពោលគឺនិព្វាន ។
គ្រប់ជាន់គ្រប់ជាតិ កុំឲ្យខ្ញុំឃ្លាត ពីសីលនឹងទាន
គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពាន
ដល់ស្ថានថ្លៃថ្លា ។
ខ្ញុំជូនមគ្គផល ចំពោះទៅដល់ មាតាបីតា
គុណគ្រូឧប- ជ្ឈាយាចារ្យ គុណញាតិកា

ប្រាំពីរសន្តាន ។

ជីដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកស្ថាន
ខ្ញុំជូនមគ្គផល កុសលថ្កើងថ្កាន សូមសុខក្សេមក្សាន្ត
ដល់ស្ថានផុតទុក្ខ ។

ខ្ញុំសូមសច្ចា កើតជាតិណា ៗ សូមឲ្យបានសុខ
សូមមានបញ្ញា ភ្លឺថ្លាមុះមុត រួចផុតពីទុក្ខ
ដល់និព្វានហោង ។

**ទ្វារពី** នឹងសេចក្តីប្រែ សម្រាប់អធិដ្ឋាន ឧទ្ទិសផលបុណ្យផ្សេង ៗ

**សុទិន្នំ វត ទោ ទានំ សព្វសម្បត្តិសិទ្ធកំ និព្វានសច្ចកំ អាសវក្ខយាវហំ ហោតុ អនាគតេ កាលេ ។**

វីទាននៃយើងខ្ញុំទាំងឡាយនេះ ដែលបានបូជាហើយដោយប្រពៃ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងពួង ទាំងសូមឲ្យបានជាបច្ច័យនាំមក នូវធម៌ជាទីអស់ទៅនៃអាសវក្កិលេសគឺព្រះនិព្វាន ឰដ៏អនាគតកាលទៅខាងមុខនោះហោង ។

## មួយបែបទៀតថា

**ឥទំ វត ទោ បុញ្ញំ អាសវក្ខយាវហំ ហោតុ អនាគតេ កាលេ ។**

វីបុណ្យរបស់យើងខ្ញុំទាំងឡាយនេះ សូមឲ្យបានជាបច្ច័យនាំមក នូវធម៌ជាទីអស់ទៅនៃអាសវក្កិលេសគឺព្រះនិព្វាន ឰដ៏អនាគតកាល

ទៅខាងមុខនោះហោង ។

## មួយបែបទៀតថា

**ឥទំ នោ ទានំ អាសវក្ខយាវហំ ហោតុ ។**

វិទាននៃយើងខ្ញុំទាំងឡាយនេះ ដែលបានបូជាហើយដោយប្រពៃ សូមឲ្យបានជាបច្ច័យនាំមកនូវធម៌ជាទីអស់ទៅនៃអាសវៈគឺកិលេសទាំងពួង-ហោង ។

## បាលីឧទ្ទិសផ្សាយចំពោះញាតិ

**ឥទំ នោ ទានំ ហោតុ សុខិតា ហោន្តុ ញាតយោ**

វិទាននៃយើងខ្ញុំទាំងឡាយនេះ ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយបាននូវសេចក្ដីសុខ ។

## សុមង្គលគាថា

**ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា**
**សព្វពុទ្ធានុភាវេន សោត្ថិ ហោតុ និរន្តរំ**

**ហោតុ សព្វំ សុមង្គលំ** សុមង្គលគឺសេចក្ដីចំរើនដ៏ល្អគ្រប់យ៉ាងចូរមានដល់ខ្ញុំ **រក្ខន្តុ សព្វទេវតា** ទេវតាទាំងពួងទាំងឡាយចូររក្សានូវខ្ញុំ **សព្វពុទ្ធានុភាវេន** ដោយអានុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ **សោត្ថិ ហោតុ និរន្តរំ** សូមសិរីសួស្ដីចូរមានដល់ខ្ញុំឲ្យបានគ្រប់ពេល កុំបីមានចន្លោះឡើយ ។

**ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា**
**សព្វធម្មានុភាវេន សោត្ថិ ហោតុ និរន្តរំ**

**ហោតុ សព្វំ សុមង្គលំ** សុមង្គលគឺសេចក្តីចំរើនដ៏ល្អគ្រប់យ៉ាងចូរមាន ដល់ខ្ញុំ **រក្ខន្តុ សព្វទេវតា** សូមទេវតាទាំងពួងទាំងឡាយ ចូររក្សានូវខ្ញុំ **សព្វធម្មានុភាវេន** ដោយអានុភាពនៃព្រះធម៌ទាំងពួង **សោត្ថិ ហោតុ និរន្តរំ** សូមសិរីសួស្តីចូរមានដល់ខ្ញុំឲ្យបានគ្រប់ពេលកុំបីមានចន្លោះឡើយ ។

**ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា**

**សព្វសង្ឃានុភាវេន សោត្ថិ ហោតុ និរន្តរំ**

**ហោតុ សព្វំ សុមង្គលំ** សុមង្គលគឺសេចក្តីចំរើនដ៏ល្អគ្រប់យ៉ាងចូរមាន ដល់ខ្ញុំ **រក្ខន្តុ សព្វទេវតា** សូមទេវតាទាំងពួងទាំងឡាយ ចូររក្សានូវខ្ញុំ **សព្វសង្ឃានុភាវេន** ដោយអានុភាពនៃព្រះសង្ឃទាំងពួង **សោត្ថិ ហោតុ និរន្តរំ** សូមសិរីសួស្តីចូរមានដល់ខ្ញុំឲ្យបានគ្រប់ពេល កុំបីមានចន្លោះឡើយ ។

ចប់ដោយសង្ខេប

## វិធីសមាទាននិច្ចសីល

ពុទ្ធសនិកជន ដែលបានដល់ព្រះត្រៃសរណគមន៍ បានឡើងនាមបញ្ញត្តិជាឧបាសក ឬ ឧបាសិកាហើយ កាលបើនឹងសមាទាននូវនិច្ចសីល គឺសីល៥ ជាបច្ចេកសមាទាន អំពីបុគ្គលដទៃ គឺភិក្ខុ ឬ សាមណេរនោះ គប្បីសូត្រនមស្សការថ្វាយបង្គំ រំលឹកដល់គុណព្រះរតនត្រៃ ដោយបទសង្ខេបជាមុនរួចហើយត្រូវសូមនូវនិច្ចសីលព្រមទាំងព្រះត្រៃសរណគមន៍ ចំពោះនឹងភិក្ខុ ឬ សាមណេរ ដែលខ្លួននឹងសមាទាននោះថា ៖

**ឱកាស {អហំ / មយំ} ភន្តេ វិសុំវិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចា {មិ / ម} {ទុតិ / តតិ} យម្បិ {អហំ / មយំ} ភន្តេ វិសុំវិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចា {មិ / ម}**

ប្រែថា សូមគោរព បពិត្រព្រះករុណាដ៏ចំរើន {ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទ..} សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បី

ប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, បពិត្រព្រះករុណាដ៏ចំរើន ខ្ញុំព្រះករុ-
ណា
} សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃ
ណាទាំងឡាយ

សរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា ជាគម្រប់ { ពីរដងផង / បីដងផង }

ឬក៏នឹងសូមថា **ឱកាស { អហំ / មយំ } ភន្តេ វិសុំវិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គសមនាគតំ និច្ចសីលំ យាចា { មិ / ម } អនុគ្គហំ កត្វា សីលំ ទេថ { មេ / នោ } ភន្តេ { ទុតិ / តតិ } យម្បិ**

**{ អហំ / មយំ } ភន្តេ វិសុំវិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច-ង្គសមន្នាគតំ និច្ចសីលំ យាចា { មិ / ម } អនុគ្គហំ កត្វា សីលំ**

**នេនថ { នេ / នោ } ឥនេ្ត** ប្រែថា សូមគោរព បពិត្រព្រះករុណាដ៏ចំរើន

ខ្ញុំព្រះ { ករុណា / ករុណាទ. } សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ មួយ

ដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា, បពិត្រព្រះករុណាដ៏ចំរើន សូមព្រះករុណាមេត្តា ធ្វើនូវសេចក្ដីអនុ-

គ្រោះឱ្យនូវសីលដល់ខ្ញុំព្រះ { ករុណា / ករុណាទ. } បពិត្រព្រះករុណាដ៏ចំរើន

ខ្ញុំព្រះ { ករុណា / ករុណាទ. } សូមនូវសីលប្រកបព្រមដោយអង្គ ៥ មួយអន្លើ

ដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា

ជាគម្រប់ { ពីរដងផង / បីដងផង } បពិត្រព្រះករុណាដ៏ចំរើន សូមព្រះករុណា

មេត្តាធ្វើនូវសេចក្ដីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះ { ករុណា / ករុណាទាំងឡាយ

---

សូមដូច្នេះក៏បាន តាមសេចក្ដីពេញចិត្តរបស់អ្នកសូម ។

---

កំណត់ចំណាំ= បើលោកអ្នកសមាទានតែម្នាក់ឯងត្រូវថា អហំ ថា យាចាមិ ត្រង់សេចក្ដីប្រែថា ខ្ញុំព្រះករុណា, សូមថា មេ ត្រង់ប្រែត្រូវថា ដល់ខ្ញុំព្រះ-ករុណា, បើគ្នាច្រើន តាំងពីពីរនាក់ឡើងទៅត្រូវសូមថា មយំ ថា យាចាម ត្រង់ប្រែថា (ករុណាទ.) = ខ្ញុំព្រះករុណាទាំងឡាយ, សូមថា នោ ត្រង់ប្រែថា (ករុណាទ.)=ដល់ខ្ញុំព្រះករុណាទាំងឡាយ, សូមសមាទានតែម្នាក់ក៏បាន ឬសូមថាព្រមគ្នាទាំងអស់ក៏បាន គឺ អហំ>យាចាមិ>មេ; មយំ>យាចាម>នោ

បន្ទាប់មកត្រូវថាតាមពាក្យដែល ព្រះភិក្ខុ ឬ សាមណេរ បានឱ្យក្នុងខណៈនោះមានតាំង នមោ ៣បទ ដែលមានបាលីនឹងសេចក្ដីប្រែដូចក្នុងបទនមស្សការខាងដើម ។

**ពុទ្ធំ សរណំ គច្ឆាមិ** សូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរលឹក

**ធម្មំ សរណំ គច្ឆាមិ** សូមដល់នូវព្រះធម៌ ជាទីពឹងទីរលឹក

**សង្ឃំ សរណំ គច្ឆាមិ** សូមដល់នូវព្រះសង្ឃ ជាទីពឹងទីរលឹក

| | | | |
|---|---|---|---|
| ទុតិយម្បិ | ពុទ្ធំ សរណំ គច្ឆាមិ<br>ធម្មំ សរណំ គច្ឆាមិ<br>សង្ឃំ សរណំ គច្ឆាមិ | សូមដល់នូវព្រះ | ពុទ្ធ<br>ធម៌<br>សង្ឃ |

ជាទីពឹងទីរលឹកជាគម្រប់ ពីរដងផង ។

| | | | |
|---|---|---|---|
| តតិយម្បិ | ពុទ្ធំ សរណំ គច្ឆាមិ<br>ធម្មំ សរណំ គច្ឆាមិ<br>សង្ឃំ សរណំ គច្ឆាមិ | សូមដល់នូវព្រះ | ពុទ្ធ<br>ធម៌<br>សង្ឃ |

ជាទីពឹងទីរលឹកជាគម្រប់ បីដងផង ។

បន្ទាប់មកភិក្ខុឬសាមណេរ ពោលថា តិសរណគមនំ និដ្ឋិតំ ឬថា តិសរណគមនំ បរិបុណ្ណំ < កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍ចប់បរិបូណ៌ត្រឹមប៉ុណ្ណេះ > ។ លោកអ្នកសមាទានត្រូវទទួលថា អាម ភន្តេ ប្រែថា ព្រះករុណាលោកម្ចាស់ ។ សមាទានសីលបន្ត

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាធ្វើជីវិតសត្វឱ្យធ្លាក់ចុះ គឺសម្លាប់សត្វ ។

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬ វាចា(ដោយចិត្តលួច)។

**កាមេសុមិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ការប្រព្រឹត្ត ខុសក្នុងកាមទាំងឡាយ (គឺបុរស-ស្រ្តី ដែលមានគេគ្រប់គ្រងរក្សា) ។

**មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាពោល នូវពាក្យកុហក ។

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានឹងមេរ័យ។

រួចហើយលោកឱ្យសីល ពោលដាស់តឿនក្រើនរំលឹកថា ៖

**ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ** ប្រែថា អ្នក/ អ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំង- ឡាយ ៥ នេះឱ្យប្រពៃ ត្រូវរក្សាឱ្យល្អអស់កាលជានិច្ច ដោយសេចក្តី មិនប្រមាទ គឺថា កុំបីធ្វេសប្រហែសឡើយ ។

លោកអ្នកសមាទានត្រូវទទួលថា អាម ភន្តេ ព្រះករុណាលោកម្ចាស់ ហើយលោកសំដែងអានិសង្សសីល ឱ្យស្តាប់បន្តទៅទៀតថា ៖

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**
**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ**

**ទុតិយម្បិ**
**ពុទ្ធំ សរណំ គច្ឆាមិ**
**ធម្មំ សរណំ គច្ឆាមិ** សូមដល់នូវព្រះ ពុទ្ធ ធម៌ សង្ឃ
**សង្ឃំ សរណំ គច្ឆាមិ**

ជាទីពឹងទីរលឹកជាគម្រប់ ពីរដងផង ។

**តតិយម្បិ**
**ពុទ្ធំ សរណំ គច្ឆាមិ**
**ធម្មំ សរណំ គច្ឆាមិ** សូមដល់នូវព្រះ ពុទ្ធ ធម៌ សង្ឃ
**សង្ឃំ សរណំ គច្ឆាមិ**

ជាទីពឹងទីរលឹកជាគម្រប់ បីដងផង ។

បន្ទាប់មកភិក្ខុឬសាមណេរ ពោលថា តិសរណគមនំ និដ្ឋិតំ ឬថា តិសរណគហនំ បរិបុណ្ណំ < កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍ចប់បរិបូណ៌ត្រឹមប៉ុណ្ណេះ > ។ លោកអ្នកសមាទានត្រូវទទួលថា អាម ភន្តេ ប្រែថា ព្រះករុណាលោកម្ចាស់ ។ សមាទានសីលបន្ត

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាធ្វើជីវិតសត្វឱ្យធ្លាក់ចុះ គឺសម្លាប់សត្វ ។

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬ វាចា(ដោយចិត្តលួច)។

**កាមេសុមិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ការប្រព្រឹត្ត ខុសក្នុងកាមទាំងឡាយ (គឺបុរស-ស្ត្រី ដែលមានគេគ្រប់គ្រងរក្សា) ។

**មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាពោល នូវពាក្យកុហក ។

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានឹងមេរ័យ។

រួចហើយលោកឱ្យសីល ពោលដាស់តឿនក្រើនរំលឹកថា ÷

**ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ** ប្រែថា អ្នក/ អ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំង-ឡាយ ៥ នេះឱ្យប្រពៃ ត្រូវរក្សាឱ្យល្អអស់កាលជានិច្ច ដោយសេចក្តី មិនប្រមាទ គឺថា កុំបីធ្វេសប្រហែសឡើយ ។

លោកអ្នកសមាទានត្រូវទទួលថា អាម ភន្តេ ព្រះករុណាលោកម្ចាស់ ហើយលោកសំដែងអានិសង្សសីល ឱ្យស្តាប់បន្តទៅទៀតថា ÷

**សីលេន សុគតី យន្តិ សីលេន ភោគសម្បទា**
**សីលេន និព្វុតី យន្តិ តស្មា សីលំ វិសោធយេ**

**ទុតិយម្បិ** { **ពុទ្ធំ សរណំ គច្ឆាមិ**<br>**ធម្មំ សរណំ គច្ឆាមិ**<br>**សង្ឃំ សរណំ គច្ឆាមិ** } សូមដល់នូវព្រះ { ពុទ្ធ<br>ធម៌<br>សង្ឃ }

ជាទីពឹងទីរលឹកជាគម្រប់ ពីរដងផង ។

**តតិយម្បិ** { **ពុទ្ធំ សរណំ គច្ឆាមិ**<br>**ធម្មំ សរណំ គច្ឆាមិ**<br>**សង្ឃំ សរណំ គច្ឆាមិ** } សូមដល់នូវព្រះ { ពុទ្ធ<br>ធម៌<br>សង្ឃ }

ជាទីពឹងទីរលឹកជាគម្រប់ បីដងផង ។

បន្ទាប់មកភិក្ខុឬសាមណេរ ពោលថា តិសរណគមនំ និដ្ឋិតំ ឬថា តិសរណគហនំ បរិបុណ្ណំ < កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍ ចប់បរិបូណ៌ត្រឹមប៉ុណ្ណេះ > ។ លោកអ្នកសមាទានត្រូវទទួលថា អាម ភន្តេ ប្រែថា ព្រះករុណាលោកម្ចាស់ ។ សមាទានសីលបន្ត

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាធ្វើជីវិតសត្វឱ្យធ្លាក់ចុះ គឺសម្លាប់សត្វ ។

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬ វាចា(ដោយចិត្តលួច)។

**កាមេសុមិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ (គឺបុរស-ស្ត្រី ដែលមានគេគ្រប់គ្រងរក្សា) ។

**មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យកុហក ។

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានឹងមេរ័យ។

រួចហើយលោកឱ្យសីល ពោលដាស់តឿនក្រើនរំលឹកថា ÷

**ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ** ប្រែថា អ្នក/ អ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំង-ឡាយ ៥ នេះឱ្យប្រពៃ ត្រូវរក្សាឱ្យល្អអស់កាលជានិច្ច ដោយសេចក្តីមិនប្រមាទ គឺថា កុំបីធ្វេសប្រហែសឡើយ ។

លោកអ្នកសមាទានត្រូវទទួលថា អាម ភន្តេ ព្រះករុណាលោកម្ចាស់ ហើយលោកសំដែងអានិសង្សសីល ឱ្យស្តាប់បន្តទៅទៀតថា ÷

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**
**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ**

ប្រែថា សត្វទាំងឡាយ ទៅកាន់ស្ថានសួគ៌បានក៏ព្រោះសីល សត្វទាំងឡាយ បានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វាន ក៏ព្រោះសីល ព្រោះហេតុនោះ បុគ្គលជាសប្បុរស គប្បីជម្រះនូវសីលឱ្យបរិសុទ្ធ កុំឱ្យសៅហ្មង ។

អស់លោកអ្នកសមាទានត្រូវទទួលថា សាធុ ប្រែថា ប្រពៃហើយ ។

ចប់ដោយសង្ខេបវិធីសមាទាននិច្ចសីលតែប៉ុណ្ណេះ

---

## វិធីសមទានឧបោសថសីល

ឧបាសក ឧបាសិកា ជាអ្នករក្សានូវឧបោសថសីល កាលបើដល់ថ្ងៃជិតនឹងរក្សានូវឧបោសថសីល គឺថ្ងៃមុន ១ ថ្ងៃដែលកំណត់ថាព្រឹកឡើងនឹងរក្សានូវឧបោសថសីលនោះ គប្បីចាត់ចែងការងារដែលគួរនិងចាត់ចែង មានវិធីចាត់ចែងនូវអាហារជាដើម ដែលជាការងារ គឺខ្លួននឹងត្រូវធ្វើ ឬ នឹងត្រូវប្រើឱ្យគេធ្វើក្នុងថ្ងៃស្អែក គឺក្នុងថ្ងៃឧបោសថកាលឱ្យហើយក្នុងថ្ងៃនោះមុន តែកុំចាត់ចែងការងារ ដែលមិនប្រកបដោយធម៌ ដែលជាការងារ គឺខ្លួនជា ឧបាសក ឧបាសិកា មិនគួរនឹងចាត់ចែងនោះឡើយ, លុះដល់ព្រឹកឡើងជាថ្ងៃឧបោសថកាល ត្រូវរក្សានូវឧបោសថសីល គប្បីភ្ញាក់ឡើងពីព្រលឹម ហើយខ្ពុរមាត់ ជម្រះធ្មេញឱ្យស្អាតរួចហើយ, បើបានសមាទានឧបោសថសីល ក្នុងវេលានោះ

ក៏ជាការប្រពៃ បើឃើញថានឹងសមាទាន ពីព្រលឹមនោះមិនទាន់ទេ ក៏គប្បីកំណត់នូវឧបោសថកាល គឺកាលជាទីរក្សានូវឧបោសថសីល ក្នុង ១ ថ្ងៃ ១ យប់នោះដោយបញ្ចេញវាចាអធិដ្ឋានថា ៖

**អជ្ជ ឧបោសថោ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ ឧបោសថិ { កោ / កា } ភវិស្សាមិ** ប្រែថា ថ្ងៃនេះជាថ្ងៃ ត្រូវរក្សានូវឧបោសថសីល, ខ្លួនអញនឹងជាអ្នករក្សានូវឧបោសថសីល អស់ថ្ងៃនេះ និងយប់នេះ ។

បើឧបាសកត្រូវថា ឧបោសថិកោ, បើឧបាសិកា ត្រូវថា ឧបោសថិកា ។ បើមិនចេះភាសាបាលី នឹងអធិដ្ឋានតាមភាសារបស់ខ្លួនៗ ក៏គួរដោយពិត, លុះអធិដ្ឋានកំណត់កាលដូច្នេះរួចហើយ ត្រូវតាំងវិរតិចេតនា វៀរចាកសីលភេទ គឺហេតុដែលជាទីទម្លាយនូវសីលនោះៗ ឱ្យគ្រប់សិក្ខាបទទាំង ៨, កាលបើបានអធិដ្ឋាន ដូច្នេះរួចហើយតអំពីពេលនោះមក ក៏គប្បីសមាទាននូវឧបោសថសីល អំពីបុគ្គលដទៃមានព្រះភិក្ខុ សាមណេរជាដើម តាមកាលដ៏សមគួរចុះ បើទុកជាដល់ពេលព្រះអាទិត្យរះខ្ពស់ឡើងប្រមាណពេញពន្លឺធំ បានសមាទានក្តីក៏ឈ្មោះថាបានសមាទានដោយប្រពៃ, ឈ្មោះថាបានរក្សានូវឧបោសថសីល ពេញកាលកំណត់ ១ថ្ងៃ ១ យប់ ដោយបរិបូណ៌ ព្រោះអ្នក-

សមាទានបានធ្វើនូវឧបោសថកាលមិនឱ្យខ្វះខាត ទាំងវិរតិចេតនា សោតក៏កើតក្លាយបរិបូណ៌ក្នុងសន្តាន នឹងបានផលអានិសង្សច្រើន ។

កាលបើឧបាសក ឧបាសិកានឹងសមាទាននូវឧបោសថសីល ប្រកបដោយអង្គប្រាំ ៨ ជាបច្ចេកសមាទាន អំពីបុគ្គលដទៃ មានព្រះភិក្ខុឬសាមណេរនោះ គប្បីសូត្រនមស្សការថ្វាយបង្គំរំលឹកគុណព្រះរតនត្រ័យដោយបទសង្ខេបជាមុនរួចហើយ ត្រូវសូមឧបោសថសីល ព្រមទាំងព្រះត្រៃសរណគមន៍ ចំពោះនឹងព្រះភិក្ខុ ឬ សាមណេរ ដែលខ្លួននិងសមាទាននោះថា ÷

**ឱកាស { អហំ / មយំ } ភន្តេ វិសុំវិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ យាចា { មិ ... ទុតិ / ៗ / ម ... តតិ } យម្បិ { អហំ / មយំ } ភន្តេ វិសុំវិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ យាចា { មិ / ម }** ៗ ប្រែ- ដូចក្នុងវិធីសូមនិច្ចសីលខាងដើម ប្លែកគ្នាតែត្រង់ពាក្យថា អដ្ឋ សីលានិ ប្រែថា នូវសីលទាំងឡាយ ៨ ។

ឬ នឹងសូមថា **ឱកាស** { **អហំ** / **មយំ** } **ភន្តេ វិសុំវិសុំរក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចា** { **មិ** / **ម** } **អនុគ្គហំ កត្វា សីលំ ទេថ** { **មេ** / **នោ** } **ភន្តេ**

**ទុតិ** / **តតិ** **យម្បិ** { **អហំ** / **មយំ** } **ភន្តេ វិសុំវិសុំរក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចា** { **មិ** / **ម** } **អនុគ្គហំ កត្វា សីលំ ទេថ** { **មេ** / **នោ** } **ភន្តេ** ប្រែថា សូមគោរព បពិត្រព្រះករុណាដ៏ចំរើន ខ្ញុំព្រះ { ករុណា / ករុណាទ. } សូមនូវឧបោសថសីល ប្រកបព្រម ដោយអង្គប្រាំបី មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា បពិត្រព្រះករុណាដ៏ចំរើន សូមព្រះករុណាមេត្តាធ្វើ

នូវសេចក្ដីអនុគ្រោះឱ្យនូវសីលដល់ខ្ញុំព្រះ ករុណា/ ករុណាទាំងឡាយ ។

បពិត្រព្រះករុណាដ៏ចំរើន ខ្ញុំព្រះ { ករុណា / ករុណាទ. } សូមនូវឧបោសថសីល

ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បី

ប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា ជាគម្រប់ { ពីរដងផង / បីដងផង } បពិត្រ

ព្រះករុណាដ៏ចំរើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្ដីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា / ករុណាទាំងឡាយ ។

សូមដូច្នេះក៏បាន តាមសេចក្ដីពេញចិត្តរបស់អ្នកសូម បន្ទាប់មកព្រះភិក្ខុ ឬ សាមណេរ ឱ្យនូវត្រៃសរណគមន៍ ទាំង ៣ បទចប់ហើយ រួចទទួលនូវសិក្ខាបទទាំង ៨ ដូចមានតទៅនេះ ÷

**១- បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ**

សេចក្ដីប្រែ ដូចមុន ។

**២- អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ**

សេចក្ដីប្រែដូចមុន ។

**អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ** ប្រែថា ខ្ញុំព្រះ

សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តិនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម ។

**៤-មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ** ប្រែដូចខាងដើម

**៥-សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** សេចក្ដីប្រែដូចមានខាងដើម ។

**៦- វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាបរិភោគនូវអាហារ ក្នុងកាលខុស ។

**៧- នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយារាំនិងច្រៀងនឹងប្រគំ និងមើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ និងកិរិយាទ្រទ្រង់ និងប្រដាប់ និងតាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រងនិងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។

**៨- ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកទីសេនាសនៈ ដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។

រួចហើយអស់លោកអ្នកសមាទានត្រូវសូត្រកំណត់ឧបោសថកាលថា

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ** ប្រែថា ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ដ៏ប្រកបព្រមដោយអង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តទុកហើយនេះ ដើម្បីនឹងរក្សាឱ្យបរិបូណ៌ប្រពៃ អស់កាលកំណត់ថ្ងៃនេះនិងយប់នេះ សូមកុសលចូរជាឧបនិស្ស័យ ធ្វើឱ្យច្បាស់នូវព្រះនិព្វាន ព្ធដ៏អនាគតកាលខាងមុខនោះហោង ។

បន្ទាប់មក ភិក្ខុ ឬ សាមណេរ លោកពោលតឿនរំលឹក ថា ÷ **ឥមានិ អដ្ឋ សិក្ខាបទានិ ឧបោសថសីលវសេន ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ** ប្រែថា អ្នក / អ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៨ នេះឱ្យប្រពៃ ត្រូវរក្សាឱ្យល្អ ដោយអំណាចនៃឧបោសថសីល អស់កាលកំណត់ត្រឹម ១ ថ្ងៃ ១ យប់នេះ ដោយសេចក្ដីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។អ្នកសមាទានទទួលថា **អាម ភន្តេ** ប្រែដូចមុន

លោកអ្នកឱ្យសីល ពោលតទៅទៀតថា ÷

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**
**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ**

សេចក្ដីប្រែដូចមុន ។ អ្នកសមាទានត្រូវទទួលថា សាធុ ប្រែដូចមុន ។

ចប់វិធីសមាទានសីលដោយសង្ខេប

# ពិធីកម្មក្នុងព្រះពុទ្ធសាសនា

ឧបាសក ឧបាសិកា ទាយក ទាយិកា ឬ លោកអ្នកដែលជាប្រមុខចាត់ការត្រូវចេះត្រូវយល់ក្នុងពិធីកម្មនោះៗ មានកិច្ចរៀបចំអាសនៈ ព្រះពុទ្ធរូប នឹងអាសនៈសម្រាប់ព្រះសង្ឃ, អាសនៈព្រះពុទ្ធរូបត្រូវរៀបដាក់ខាងស្តាំដៃនៃអាសនៈព្រះសង្ឃ (គឺព្រះសង្ឃគង់នៅខាងឆ្វេងព្រះពុទ្ធរូប)មានរៀបចំគ្រឿងសក្ការៈបូជាព្រះរតនត្រ័យ មានទៀន ធូប កម្រងផ្កា ថូផ្កា ឬវត្ថុផ្សេងៗ ដែលជាគ្រឿងលំអរលើអាសនៈ ។

បន្ទាប់លោកអាចារ្យ ឬ សាមីដើមបុណ្យបានធ្វើបដិសណ្ឋារៈដល់ភ្ញៀវ នឹងការទទួលបដិសណ្ឋារៈគារវៈដល់ព្រះភិក្ខុសង្ឃ រួចស្រេចហើយលោកតាអាចារ្យ ឬ លោកអ្នកប្រមុខនៃបុណ្យ ចាប់ផ្តើមនមស្សការព្រះរតនត្រ័យ សមាទានសីល, អារាធនាព្រះសង្ឃចំរើនព្រះបរិត្ត មានជាអាទិ៍÷ < ពាក្យអារាធនាចំរើនព្រះបរិត្ត >

ឧកាស វិបត្តិប្បដិពាហាយ សព្វ សម្បត្តិ សិទ្ធិយា
សព្វ ទុក្ខវិនាសាយ បរិត្តំ ព្រូ ថ មង្គលំ,
វិបត្តិប្បដិពាហាយ សព្វ សម្បត្តិ សិទ្ធិយា
សព្វ ភយវិនាសាយ បរិត្តំ ព្រូ ថ មង្គលំ,
វិបត្តិប្បដិពាហាយ សព្វ សម្បត្តិ សិទ្ធិយា
សព្វ រោគវិនាសាយ បរិត្តំ ព្រូ ថ មង្គលំ ។

ប្រែថា សូមព្រះករុណាទាំងឡាយ ចំរើននូវព្រះបរិត្តជាជ័យមង្គល ដើម្បីនឹងការពារបញ្ចៀសនូវវិបត្តិ គឺសេចក្ដីអន្តរាយទាំងពួង ដើម្បីនឹងឱ្យបានសម្រេចនូវសម្បត្តិគ្រប់យ៉ាង ដើម្បីនឹងញ៉ាំង ទុក្ខ ភ័យ រោគ ទាំងអស់ឱ្យវិនាសបាត់ទៅ ។

ព្រះសង្ឃបានចំរើនព្រះបរិត្តចប់ហើយ បើមានសម្ដែងធម្មទេសនា ត្រូវរៀបចំគ្រែអាសនៈឱ្យសមគួរប្រពៃដល់ទីកន្លែង ហើយអារាធនាធម្មទេសនាជាភាសាបាលី ឬសូត្រជាសម្រាយក៏បាន តាមការគួរ ។

( អារាធនាជាភាសាបាលី បែបសង្ខេប )

**ព្រហ្មា ច លោកា ធិបតីសហម្បតិ្ត កតញ្ជលី អន្ធិវរំ អយាចថ។**
**សន្តីធ សត្តាប្បរជក្ខជាតិកា ទេសេតុ ធម្មំ អនុកម្បិមំ បជំ ។**
**សន្ធម្មតេរី ចិនយញ្ច កាយំ សុត្តញ្ច ពន្ធំ អតិធម្ម ចម្មំ ។**
**អារោកយន្តោ ចតុសច្ចឧណ្ហំ បវោធនេយ្យេ បរិសាយ មវេជ្ឈ ។**

លុះព្រឹកឡើងជាកិច្ចថ្វាយចង្ហាន់ព្រះសង្ឃ ដែលអស់លោកទាំងឡាយនិយមធ្វើ សូត្របាលីវេរ ឬភាសាសម្រាយ, ទៅតាមកម្មវិធីបុណ្យ មានភត្តាហារទាំង ១៤ យ៉ាងគឺ ÷

១)- *សង្ឃភត្តំ* ភត្តដែលប្រគេនដល់សង្ឃ ,

២)- *ឧទ្ទិសភត្តំ* ភត្តដែលប្រគេនដល់ភិក្ខុ ១ អង្គក្ដី ២ អង្គក្ដី ៣ អង្គក្ដី ជាដើម តាមពាក្យដែលសង្ឃចាត់ឱ្យ .

៣)- និមន្តនភត្តំ ភត្តដែលប្រគេនដល់ភិក្ខុដែលបាន និមន្តមក,

៤)- សលាកភត្តំ ភត្តដែលប្រគេនដល់ភិក្ខុច្រើនអង្គ ដែលគេសរសេរឈ្មោះក្នុងស្លាកហើយចាប់ ,

៥)- បក្ខិកភត្តំ ភត្តដែលគេប្រគេនដល់ភិក្ខុសង្ឃ ក្នុងថ្ងៃបក្សទាំងពីរ គឺសុក្កបក្ស ចំណែកខាងខ្នើត, កាឡបក្ស ចំណែកខាងរនោច, ក្នុងមួយបក្សប្រគេនតែមួយថ្ងៃ គឺថ្ងៃណាមួយមិនមានកំណត់;

៦)-ឧបោសថិកភត្តំ ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ ក្នុងថ្ងៃឧបោសថ,

៧)- បាដិបទិកភត្តំ ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ ក្នុងថ្ងៃ ១ កើត ឬ ថ្ងៃ ១ រោច ,

៨)-អាគន្តុកភត្តំ ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ ដែលទើបមកដល់ថ្មី

៩)- គមិកភត្តំ ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ ដែលមានដំណើរទៅកាន់ទីណាមួយ ,

១០)- គិលានភត្តំ ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ ដែលមានជម្ងឺ ,

១១)-គិលានុបដ្ឋាកភត្តំ ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ ដែលជាអ្នករក្សាជម្ងឺភិក្ខុសាមណេរផងគ្នា ។

១២)-និច្ចភត្តំ ភត្តដែលត្រូវប្រគេនជានិច្ច ដល់ភិក្ខុសង្ឃ ។

១៣)-កុដិកភត្តំ ភត្តំដែលប្រគេនដល់ភិក្ខុសង្ឃក្នុងទីលំនៅ មានកុដិជាដើម. ភត្តនេះហៅបានតាមឈ្មោះទីកន្លែងដែលសង្ឃនៅ ។

១៤)-វារកភត្តំ ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ ដោយចាត់ជាវេន ។

- ភត្តទាំង ១៤ ប្រការនេះ បើទាយក ទាយិកា ប្រាថ្នានឹងវេរភត្តណាមួយ ឱ្យដាក់ឈ្មោះភត្តនោះត្រង់បាលីដែលវង់ក្រចកយ៉ាងនេះ (.......) ចុះ ។

## បាលីវេរភត្ត

**អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស្ស ឥមំ ( សង្ឃភត្តំ ) សបរិក្ខារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម គុណវន្តានំ យោ ឥមំ ( សង្ឃភត្តំ ) អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោ-ទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្ទេន ។ ទុតិយម្បិ.........។ តតិយម្បិ.......។**

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើនអើយ វិចង្ហាន់បិណ្ឌបាត នៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ យើងខ្ញុំទាំងឡាយសូមឧទ្ទិស្សចំពោះ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតានិងបិតាជាដើម ហើយយើងខ្ញុំទាំងឡាយ (វេរនូវសង្ឃភត្តនេះ) ព្រមទាំងបរិក្ខារ ប្រគេនដល់ព្រះសង្ឃ មានព្រះពុទ្ធរូបជាប្រធាន សូមលោកអ្នកដ៏មានគុណទាំងឡាយ មាន មាតានិងបិតាជាដើមនោះ សំគាល់ (នូវសង្ឃភត្តនេះ) ថាដូចជារបស់

នៃខ្លួន ហើយសូមអនុមោទនាយកចុះ លុះអនុមោទនារួចហើយ សូមឱ្យរួចរដោះចាកទុក្ខទោស (នឹងពៀរវេរា) ទាំងពួង ឱ្យបានសម្រេចដោយសម្បត្តិទាំងឡាយបីប្រការ គឺសម្បត្តិមនុស្ស ១ សម្បត្តិទេវតា១ សម្បត្តិព្រះនិព្វាន ១ ដោយសមគួរតាមសេចក្តីប្រាថ្នា របស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្សដែលហូរជូនទៅមិនដាច់នេះហោង ។ អស់វារៈពីរដងផង ។ អស់វារៈបីដងផង ។

វេរសង្ឃទាន

**មយំ ភន្តេ ឥមានិ ខាទនីយភោជនីយានិ សបរិក្ខារានិ សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមានិ ខាទនីយភោជនីយានិ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ ហិតាយ សុខាយ ។ ទុតិយម្បិ .........។ តតិយម្បិ .........។**

ប្រែថា បពិត្រព្រះគម្តែងដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយបានតាក់តែងនូវវត្ថុទាំងឡាយ មានខាទនីយភោជនីយាហារ គឺបង្អែមនឹងចំអាបជាដើមនេះហើយបង្អោនមកវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះគម្តែងសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយកនូវវត្ថុទាំងឡាយ មានបង្អែមនឹងចំអាបជាដើមនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ដើម្បីសេចក្តីសុខគ្រប់ប្រការដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ អស់វារៈពីរដងផង ។ អស់វារៈបីដងផង ។

## វេរគណៈទាន

**មយំ ភន្តេ ឥមានិ ខាទនីយភោជនីយានិ សជ្ជេត្វា សីលវន្តានំ ទេម សាធុ ភន្តេ សីលវន្តោ ឥមានិ ខាទនីយភោជនីយានិ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ..............។ តតិយម្បិ................ ។**

ប្រែថា បពិត្រព្រហករុណាទាំងឡាយដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយបានតាក់តែងនូវវត្ថុទាំងឡាយ មានខាទនីយភោជនីយាហារ គឺបង្អែមនឹងចំអាបជាដើមនេះ ហើយបង្អោនមកវេរប្រគេនដល់លោកម្ចាស់អ្នកដ៏មានសីលទាំងឡាយ បពិត្រព្រះករុណាទាំងឡាយដ៏ចំរើន សូមលោកម្ចាស់អ្នកដ៏មានសីលទាំងឡាយ ទទួលយកវត្ថុទាំងឡាយមានបង្អែមនឹងចំអាបជាដើមនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ អស់វារៈពីរដងផង ។ អស់វារៈបីដងផង ។

## វេរភត្តចំពោះព្រះភិក្ខុ ១ អង្គ

**មយំ ភន្តេ ឥមានិ ខាទនីយភោជនីយានិ សជ្ជេត្វា សីលវន្តា ទេម សាធុ ភន្តេ សីលវា ឥមានិ ខាទនីយភោជនីយានិ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ................។ តតិយម្បិ ...................... ។**

ប្រែថា បពិត្រព្រះករុណាដ៏ចំរើនអើយ (នើយ) យើងខ្ញុំទាំងឡាយបាន តាក់តែងនូវវត្ថុទាំងឡាយ មានខាទនីយភោជនីយាហារ គឺ........។ល។ មានន័យដូចវេរគណៈភោជន ដូរតែពាក្យដែលថា > ដល់ព្រះករុណា ទាំងឡាយ>ផ្លាស់ទៅជា>ដល់ព្រះករុណា, បពិត្រព្រះករុណាដ៏ចំរើន សូមលោកអ្នកដ៏មានសីលទទួលយក....។ល។ មានសេចក្តីប្រែដូចគ្នា នឹងវេរខាងដើម ។

## វេរផ្កាហិរញ្ញវត្ថុ

**មយំ ភន្តេ សទ្ធាបសន្នា ឥធ អារាមេ (សេនាសនករណត្ថាយ)[១] ឥមានិ ហិរញ្ញបុប្ផានិ ឥធានេត្វា សង្ឃស្ស បវារេម ។ សាធុ ភន្តេ សង្ឃោ វិនយានុរូបំ កប្បិយការកស្ស ហត្ថេ ឋបិតានិ ឥមានិ ហិរញ្ញបុប្ផានិ បដិជានាតុ មាតាបិតាទីនំ គុណវន្តាញ្ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ..។តតិ..។**

ប្រែថា បពិត្រព្រះគម្តែងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ មានសទ្ធាជ្រះថ្លា បាននាំនូវផ្កាហិរញ្ញវត្ថុទាំងឡាយនេះ សូមបវរណា ចំពោះព្រះសង្ឃ (ដើម្បីកសាងសេនាសនៈ)[១] ក្នុងវត្តនេះ ។

បពិត្រព្រះគម្តែងសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលដឹងនូវផ្កាហិរញ្ញវត្ថុ ទាំងឡាយនេះ ដែលយើងខ្ញុំទាំងឡាយ បានទុកដាក់ហើយ ក្នុងដៃនៃ កប្បិយការកៈ ដ៏សមគួរដល់វិន័យ ដើម្បីសេចក្តីចំរើន ដើម្បីជា-

(១)- ត្រង់កណ្តាលវង់ក្រចកសម្រាប់បញ្ចូល បាលីឈ្មោះវត្ថុដែលត្រូវវេរ

ប្រយោជន៍ ដើម្បីសេចក្តីសុខគ្រប់ប្រការ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតានិងបីតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង។ អស់វារៈពីរដងផង..។អស់វារៈបីដងផង,

## វេរចតុបច្ច័យ ជាសង្ឃទាន

**មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ....។ តតិយម្បិ....។**

ប្រែថា បពិត្រព្រះគម្តែងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយបាននាំនូវបច្ច័យទាំងឡាយ ៤ នេះ មកដំកល់ទុកក្នុងទីនេះ ហើយវេរប្រគេនដល់ព្រះសង្ឃ បពិរតព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយកនូវបច្ច័យទាំងឡាយ ៤ នេះ, ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ អស់វារៈពីរដងផង......។ អស់វារៈបីដងផជ ....។

## វេរចតុបច្ច័យចំពោះភិក្ខុមួយរូប

**មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា អាយស្មតោ ទេម, សាធុ ភន្តេ អាយស្មា ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ..។ តតិយម្បិ....។**

ប្រែថា បពិត្រព្រះករុណាម្ចាស់ដ៏ចំរើន យើងខ្ញុំទាំងឡាយបាននាំ

នូវបច្ច័យទាំងឡាយ ៤នេះ មកដំកល់ទុកក្នុងទីនេះ ហើយវេរប្រគេនដល់ព្រះករុណាម្ចាស់ដ៏មានអាយុ, បពិត្រព្រះករុណាម្ចាស់ដ៏ចំរើន សូមព្រះករុណាទទួលយកនូវបច្ច័យទាំងឡាយ ៤នេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំង-ឡាយ អស់កាលជាអង្វែងទៅហោង ។ អស់វារៈពីរដងផង.........។ អស់វារៈបីដងផង ..........។

## វេររោងឧបោសថ គឺព្រះវិហារ

**មយំ ភន្តេ ( ឥមំ ឧបោសថាគារំ ) ការេត្វា ឧបោសថបវារណាទិ-សង្ឃកម្មករណត្ថាយ ចតុទ្ទិសស្ស ភិក្ខុសង្ឃស្ស ទេម សាធុ ភន្តេ ភិក្ខុសង្ឃោ ( ឥមំ ឧបោសថាគារំ ) បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ .....។ តតិយម្បិ.........។**

ប្រែថា បពិត្រព្រះគម្តែងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយបានចាតចែងធ្វើនូវ (រោងសម្រាប់ធ្វើនូវឧបោសថ) នេះ ហើយសូមវេរប្រគេនដល់ព្រះភិក្ខុសង្ឃ ដែលមកអំពីទិសទាំង ៤ ដើម្បីប្រយោជន៍ដល់កិរិយាធ្វើនូវសង្ឃកម្ម មានឧបោសថកម្ម និងបវារណាកម្មជាដើម បពិត្រព្រះគម្តែងសង្ឃដ៏ចំរើន សូមព្រះភិក្ខុសង្ឃទទួលយកនូវ (រោងសម្រាប់ធ្វើនូវឧបោសថ) នេះ,ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែងទៅហោង ។ អស់វារៈពីរដងផង ...។ អស់វារៈបីដងផង....។

វេរកឋិនទាន ដល់ព្រះសង្ឃ

**ឥមំ ទុស្សំ កឋិនចីវរំ សង្ឃស្ស ទេម,**

**ទុតិយម្បិ ភន្តេ ឥមំ ទុស្សំ កឋិនចីវរំ សង្ឃស្ស ទេម,**

**តតិយម្បិ ភន្តេ ឥមំ ទុស្សំ កឋិនចីវរំ សង្ឃស្ស ទេម ។**

ប្រែថា បពិត្រព្រះគម្តែងសង្ឃដ៏ចំរើនអើយ យើងខ្ញុំសូមវេរនូវសំពត់នេះ ជាសំពត់ដើម្បីកឋិនចីវរ ប្រគេនដល់ព្រះសង្ឃ ។

អស់វារៈពីរដងផង ....។ អស់វារៈបីដងផង .......។

បើចង់វេរថា= ឥមំ វត្ថំ កឋិនចីវរំ សង្ឃស្ស ទេម ដូច្នេះក៏បាន,

វេរគ្រឿងបរិក្ខារជាបរិវារកឋិន

**យេនម្ហាកំ កឋិនំ អត្ថតំ កឋិនានិសំសានិ តស្សេវ ទេម,**

**ទុតិយម្បិ .....។ តតិយម្បិ .........។**

ប្រែថា បពិត្រព្រះគម្តែងសង្ឃដ៏ចំរើនអើយ រីកឋិននៃយើងខ្ញុំទាំងឡាយ គឺលោកម្ចាស់អង្គណា បានទទួលកាន់យកហើយ យើងខ្ញុំទាំងឡាយ សូមវេរនូវគ្រឿងបរិក្ខារជាបរិវារនៃកឋិនទាំងឡាយ ប្រគេនដល់លោកម្ចាស់អង្គនោះ ។ អស់វារៈពីរដងផង..។ អស់វារៈបីដងផង។

លោកអាចារ្យ ឬ ទាយក ទាកយិកា ដែលជាអ្នកដឹកនាំក្នុងពិធីបុណ្យនីមួយៗ ត្រូវចេះត្រូវយល់ ក្នុងពិធីបុណ្យនោះៗ មានសូត្រនមស្សការព្រះរតនត្រ័យ សុំសីល នឹងវេរភត្តាហារប្រគេនព្រះសង្ឃជាដើម នឹងការរៀបចំអាសនៈព្រះពុទ្ធរូប នឹង-

អាសនៈព្រះសង្ឃ, ព្រោះសាមីដើមបុណ្យខ្លះគ្នាមិនសូវយល់កិច្ចការ ដែលត្រូវធ្វើ ត្រូវរៀបចំឱ្យត្រូវតាមប្រពៃណីរបស់ព្រះពុទ្ធសាសនា ដូច្នេះយើងជាអាចារ្យត្រូវជួយពន្យល់ប្រាប់ ណែនាំដោយបិយវាចា ឱ្យម្ចាស់បុណ្យរីករាយជ្រះថ្លាក្នុងកិច្ចដែលកំពុងធ្វើនោះ ៗ ។

ឈ្មោះសំពត់ ១០ យ៉ាង

១- ឥមំ តិចីវរំ នូវសំពត់ត្រៃចីវរនេះ (សំពត់មួយត្រៃ)

ឥមានិ តិចីវរានិ នូវសំពត់ត្រៃចីវរទាំងឡាយនេះ (សំពត់ច្រើនត្រៃ)

២-ឥមំ វស្សិកសាដិកំ នូវសំពត់សម្រាប់ងូតទឹកភ្លៀងនេះ(សំពត់១)

ឥមា វស្សិកសាដិកាយោ នូវសំពត់សម្រាប់ងូតទឹកភ្លៀងទាំងឡាយនេះ (សំពត់មានចំនួនច្រើន) ,

៣-ឥមំ និសីទនំ នូវសំពត់សម្រាប់ទ្រាប់អង្គុយនេះ (សំពត់ ១ )

ឥមានិ និសីទនានិ នូវសំពត់សម្រាប់ទ្រាប់អង្គុយទាំងឡាយនេះ (គឺសំពត់និសីទនៈច្រើន) ,

៤-ឥមំ បច្ចត្ថរណំ នូវសំពត់សម្រាប់ក្រាលនេះ, (សំពត់តែមួយ)

ឥមានិ បច្ចត្ថរណានិ នូវសំពត់សម្រាប់ក្រាលទាំងឡាយនេះ,(ព.ហុ)

៥-ឥមំ កណ្ឌុប្បដិច្ឆាទឹ នូវសំពត់សម្រាប់គ្របបូស ឬគ្របដំបៅនេះ,

ឥមានិ កណ្ឌុប្បដិច្ឆាទីនិ នូវសំពត់សម្រាប់គ្របបូស ឬ គ្របដំបៅទាំងឡាយនេះ (ព.ហុ.)

៦-ឥមំ មុខមុញ្ឆនចោឡំ នូវសំពត់សម្រាប់ជូតមុខ គឺកន្សែងជាបរិក្ខារនេះ ,

ឥមានិ មុខមុញ្ឆនចោឡានិ នូវសំពត់សម្រាប់ជូតមុខ គឺកន្សែងជាបរិក្ខារទាំងឡាយនេះ (ព.ហុ),

៧-ឥមំ បរិក្ខាចោឡំ នូវសំពត់តូចឬធំជាប្រមាណ ជាបរិក្ខារនេះ,

ឥមានិ បរិក្ខាចោឡានិ នូវសំពត់បរិក្ខារទាំងឡាយនេះ (ព.ហុ)

៨-ឥមំ បរិសាវនំ នូវសំពត់សម្រាប់ត្រងទឹកនេះ,

ឥមានិ បរិសាវនានិ នូវសំពត់សម្រាប់ត្រងទឹកទាំងឡាយនេះ(ព.ហុ)

៩-ឥមំ វស្សាវាសិកំ នូវសំពត់ចំណាំវស្សានេះ ,

ឥមា វស្សាវាសិកាយោ នូវសំពត់ចំណាំវស្សាទាំងឡាយនេះ(ព.ហុ)

១០-ឥមំ អច្ឆេកចីវរំ នូវសំពត់អច្ឆេកចីវរនេះ,

ឥមានិ អច្ឆេកចីវរានិ នូវសំពត់អច្ឆេកចីវរទាំងឡាយនេះ, (ព.ហុ)។

## ឈ្មោះសេនាសនៈដែលត្រូវវេរជាភាសាបាលី

ឥមំ សាលំ នូវសាលានេះ,

ឥមំ កប្បិយកុដឹ នូវកប្បិយកុដិនេះ,

ឥមំ កុដឹ នូវកុដិនេះ,

ឥមំ វិហារំ នូវកុដិធំនេះ,

ឥមំ វច្ចកុដឹ នូវបង្គន់នេះ,

## ឈ្មោះវត្ថុដែលត្រូវវេរជាភាសាបាលី

ឥមានិ នានាផលានិ នូវផ្លែឈើទាំងឡាយនេះ,

ឥមានិ តណ្ឌុលានិ នូវអង្ករទាំងឡាយនេះ,

ឥមំ គរុភណ្ឌំ នូវគរុភណ្ឌនេះ,

ឥមំ មធុំ នូវទឹកឃ្មុំនេះ,

ឥមំ តេលំ នូវប្រេងនេះ,

ឥមំ ផាណិតំ នូវទឹកអំពៅនេះ,

ឥមំ តាលោទកំ នូវទឹកត្នោតនេះ,

ឥមំ គិលានភេសជ្ជំ នូវថ្នាំសម្រាប់រក្សានូវមនុស្សឈឺនេះ;

ឈ្មោះវត្ថុទាំងឡាយ ដូចបានរៀបរាប់ខាងលើនេះបើអស់លោកប្រាថ្នានិងវេរឈ្មោះវត្ថុណាមួយសូមយកពាក្យនោះជាភាសាបាលី ឬសម្រាយមកដាក់បញ្ចូលត្រង់វង់ក្រចក (..............) ជាការស្រេចក្រៅពីនោះមានន័យដូចគ្នា ។ អស់លោកជាអ្នកដឹកនាំក្នុងកម្មវិធីបុណ្យគួរនិយាយពន្យល់សាមីដើមបុណ្យឱ្យគ្នាយល់ច្បាស់ក្នុងកិច្ចការនោះៗ

ចប់វិធីវេរភត្តដោយសង្ខេប

# អង្គនៃឧបោសថសីល

## បាណាតិបាតាមានអង្គ ៥

១- បាណោ សត្វមានជីវិត

២- បាណសញ្ញិតា សេចក្ដីដឹងថាសត្វមានជីវិត

៣- វធកចិត្តំ គិតនិងសម្លាប់

៤- ឧបក្កមោ ព្យាយាមនិងសម្លាប់

៥- តេនមរណំ សត្វស្លាប់ដោយព្យាយាមនោះ ។

## អទិន្នាទានមានអង្គ ៥

១- បរបរិគ្គហិតំ ទ្រព្យដែលម្ចាសគេហួងហែងរក្សា

២- បរបរិគ្គហិតសញ្ញិតា សេចក្ដីដឹងថាទ្រព្យនោះមានម្ចាស់របស់គេហួងហែងរក្សា,

៣- ថេយ្យចិត្តំ ចិត្តគិតនិងលួច,

៤- ឧបគ្គមោ ព្យាយាមនិងលួច,

៥- តេន ហរណំ លួចបានមកដោយព្យាយាមនោះ ។

## កាមេសុមិច្ឆាចារមានអង្គ ៤ (ក្នុងសីល ៥)

១- អគមនីយដ្ឋានិ ស្ត្រីដែលមិនគួរនឹងគប់រក គឺស្ត្រីដែលមានគេហួងហែងរក្សា ,

២- តស្មឹ សេវនចិត្តំ គឺតនិងសេពនូវមេថុនធម្មនិងស្ត្រីនោះ,

៣- ឧបក្កមោ ព្យាយាមនិងសេពនូវមេថុនធម្ម,

៤- មគ្គេនមគ្គបដិបាទនំ ញ៉ាំងមគ្គនិងមគ្គឱ្យដល់គ្នា ។

អព្រហ្មចរិយ មានអង្គ ៤ (សីលឧបោសថ)

១- ភេទនវត្ថុ វត្ថុជាទីទំលាយនូវសីលគឺទ្វារទាំង ៣០ ចំពោះទ្វារណាមួយ,

២- សេវនចិត្តំ គឺតនិងសេព,

៣- តជ្ជោវាយាមោ ព្យាយាមនិងសេពនូវមេថុនធម្មនោះ,

៤- មគ្គេនមគ្គបដិបាទនំ ញ៉ាំងមគ្គនិងមគ្គឱ្យដល់គ្នា ។

មុសាវាទ មានអង្គ ៤

១- អតថំវត្ថុ វត្ថុមិនពិត,

២- វិសំវាទនចិត្តំ គឹតនិងពោលឱ្យខុស,

៣- តជ្ជោវាយាមោ ព្យាយាមនិងពោលឱ្យខុស,

៤-បរស្សតទត្ថវិជាននំ ញ៉ាំងអ្នកដទៃឱ្យដឹងច្បាស់នូវសេចក្ដីនោះ។

សុរាមេរយ មានអង្គ ៤

១- មជ្ជនីយវត្ថុ វត្ថុជាទីតាំងនៃសេចក្ដីស្រវឹងគឺ សុរានិងមេរ័យ,

២- បាតុកម្យតាចិត្តំ គិតបំរុងនិងផឹក,

៣- តជ្ជោ វាយាមោ ព្យាយាមនិងផឹកនូវទឹកស្រវឹងនោះ,

៤- តស្ស បានំ បានផឹកនូវទឹកស្រវឹងនោះ ឱ្យកន្លងបំពង់កចូលទៅ។

## វិកាលភោជនំ មានអង្គ ៣ (សីលឧបោសថ)

១- វិកាលោ កាលខុសគឺព្រះអាទិត្យជ្រេទៅហើយ ដរាបទល់នឹងអរុណរះ ,

២- យាវកាលិកំ របស់ដែលគួរបរិភោគបានក្នុងកាល គឺតាំងពីអរុណរះឡើងដរាបដល់ថ្ងៃត្រង់,

៣- អជ្ឈោហរណំ បានលេបចូលទៅក្នុងបំពង់ក ។

## នច្ចគីត ព្រមទាំង មាលា រួមគ្នាជាសិក្ខាបទមួយមានអង្គ ៦

១- នច្ចគីតាទិ ការល្បែងមានរាំនឹងច្រៀងជាដើម,

២- កត្តុកម្យតាចិត្តំ គិតបំរុងនិងធ្វើ,

៣- សុតទស្សនត្ថាយគមនំ ទៅដើម្បីនឹងស្តាប់ ឬ មើល ហើយបានស្តាប ឬ មើល ។

៤- មាលាទិ វត្ថុសម្រាប់ប្រដាប់កាយមានផ្កាកម្រងជាដើម,

៥- ធារណឆន្ទតា សេចក្តីប្រាថ្នានិងប្រដាប់តាក់តែង,

៦- តស្សធបណំ បានប្រដាប់តាក់តែងនូវវត្ថុសម្រាប់ប្រដាប់កាយមានផ្កាកម្រងជាដើមនោះ ។

## ឧច្ចាសយន មានអង្គ ៣

១- ឧច្ចាសយន មហាសុយនំ ទីដេក ទីអង្គុយ ដ៏ខ្ពស់ ដ៏ប្រសើរហួសប្រមាណ,

២- បរិភោគចិត្តំ  គិតនិងដេក ឬអង្គុយ,

៣- បរិភោគករណំ  បានដេក ឬអង្គុយ ។

កាលបើឧបាសក ឧបាសិកា ប្រព្រឹត្តឱ្យកន្លងនូវសិក្ខាបទណាៗ លុះតែព្រមដោយអង្គក្នុងសិក្ខាបទនោះៗ ទើបបានឈ្មោះថាកន្លង បើមិនទាន់ព្រមដោយអង្គនោះ ក៏មិនបានឈ្មោះថាកន្លងនូវសិក្ខាបទនោះៗ

អង្គនច្ចសីល នឹងឧបោសថសីល ចប់តែប៉ុណ្ណេះ

អកុសលកម្មបថ ១០ (ផ្លូវនៃអំពើបាប ជាអកុសល លាមក)

កាយកម្ម ៣ (ធ្វើតាមផ្លូវកាយ)

១- បាណាតិបាតោ  កិរិយាសម្លាប់សត្វដោយកាយរបស់ខ្លួន ឬប្រើគេឱ្យសម្លាប់ដោយវាចា,

២- អទិន្នាទានំ  កិរិយាលួចលាក់ ឆក់ដណ្តើមទ្រព្យគេដោយកាយរបស់ខ្លួន ឬប្រើគេឱ្យលួចលាក់ឆក់ដណ្តើមដោយវាចា,

៣- កាមេសុមិច្ឆាចារោ  កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺធ្វើនូវមេថុនសេវននឹងស្ត្រីដែលមានគេហួងហែងរក្សា។

វចីកម្ម ៤ (ធ្វើដោយវាចា)

១- មុសាវាទោ  កិរិយាពោលនូវពាក្យកុហក,

២- បិសុណាវាចា  កិរិយាពោលនូវពាក្យញុះញង់ ស៊កសៀត បំបែកបំបាក់អ្នកដទៃ,

៣- ផរុសវាចា កិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម,

៤- សម្ផប្បលាបោ កិរិយាពោលនូវពាក្យរោចរាយឥតប្រយោជន៍។

មនោកម្ម ៣ (ធ្វើអាក្រក់ដោយផ្លូវចិត្ត)

១- អភិជ្ឈា ចិត្តសំឡឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ គឺតបំរុងនិងឱ្យបានមកជាទ្រព្យរបស់ខ្លួន,

២- ព្យាបាទោ ចិត្តចងគំនុំគំគួន គឺប៉ងនិងឱ្យអ្នកដទៃដល់នូវសេចក្ដីវិនាស,

៣- មិច្ឆាទិដ្ឋិ គំនិតយល់ខុស ហើយប្រកាន់ឡើងថាជាត្រូវ ។

អង្គ នៃអកុសលកម្មបថ ទាំង ១០

អង្គនៃ បាណាតិបាត, អទិន្នាទាន, កាមេសុមិច្ឆាចារ, នឹង មុសាវាទ, មានពោលខាងដើមហើយ ,

បិសុណាវាចា មានអង្គ ៤

១- ភិន្ទិតព្វោបរោ អ្នកដទៃដែលមានរូបគឺខ្លួនគប្បីញុះញង់បំបែក,

២- ភេទនបុរេក្ខារតា គិតនិងញុះញង់បំបែកអ្នកដទៃនោះ,

៣- តជ្ជោវាយាមោ ព្យាយាមបំបែកបំបាក់អ្នកដទៃនោះ,

៤- តស្សតទត្ថវិជ្ជាននំ ញាំងអ្នកដទៃឱ្យដឹងច្បាស់នូវដំណើរដែលញុះញង់បំបែកនោះ ។

## ផរុស្សវាចា មានអង្គ ៣

១-អក្កោសិតព្វោបរោ អ្នកដទៃដែលមានរូបគឺខ្លួនគប្បីជេរប្រទេច,

២- កុបិ្បតចិត្តំ ចិត្តខឹងរន្ធត់,

៣- អក្កោសនា បានជេរប្រទេច ។

## សម្ផប្បលាប មានអង្គ ២

១- ភារត យុទ្ធភាសិតាហករណាទីនិរត្ថកថា ពាក្យឥតប្រយោជន៍ មានរឿងចម្បាំងនៃ ភារត នឹងរឿង រាពណ៍ លួចនាងសេដាយកទៅជាដើម ។

២- តថារូបីកថាកថនំ បានពោលនូវពាក្យឥតប្រយោជន៍ មានសភាពដូច្នោះ ។

## អភិជ្ឈា មានអង្គ ២

១- បរភណ្ឌំ ទ្រព្យជារបស់អ្នកដទៃ ,

២- អត្តនោ បរិណាមនំ គឺតចង់បង្អោនទ្រព្យរបស់អ្នកដទៃនោះឱ្យបានមកជាទ្រព្យរបស់ខ្លួន ដោយកលឧបាយផ្សេង ៗ ។

## ព្យាបាទ មានអង្គ ២

១- បរសត្តោ អ្នកដទៃក្រៅពីខ្លួន ,

២- តស្សតំ តវិនាសចិន្តា គិតគំនុំគំគួន និងឱ្យអ្នកនោះដល់នូវសេចក្តីវិនាសដោយហេតុនោះ ។

## មិច្ឆាទិដ្ឋិ មានអង្គ ២

១- វត្ថុនោចគហិតាការវិបរិតតា ចិត្តប្រែប្រួល ដោយអាការខុសអំពីព្រះរតនត្រ័យជាដើម ។

២- យថាចនំតណ្ហាតិតថាភាវេនតស្សុបដ្ឋានំ គំនិតដែលយល់ខុសនោះ ឃើញខុសយ៉ាងណា ក៏ប្រកាន់សេចក្ដីខុសនោះថាជាត្រូវ ។

(អង្គអកុសលកម្មបថ ១០ចប់ប៉ុណ្ណេះ)

## កុសលកម្មបថ ១០ (ផ្លូវនៃអំពើល្អ)

### កាយកម្ម ៣

១- បាណាតិបាតា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ (មិនសម្លាប់សត្វ) ។

២- អទិន្នាទានា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬដោយវាចា (គឺមិនលួច) ។

៣- កាមេសុមិច្ឆាចារា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

### វចីកម្ម ៤

១- មុសាវាទា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

២- បិសុណាវាចាយ វេរមណី ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យញុះញង់ ស៊កសៀតបំបែកបំបាក់អ្នកដទៃ ។

៣- ផរុសាយវាចាយ វេរមណី ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោកជេរប្រទេចជាដើម,
៤- សម្ផប្បលាបា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

## មនោកម្ម ៣

១- អនភិជ្ឈា មិនមានចិត្តគិតសំឡឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃដោយគិតបំរុងនិងឱ្យបានមកជាទ្រព្យរបស់ខ្លួនឡើយ ។
២- អព្យាបាទោ មិនមានចិត្តចងគំនុំគំគួន គិតប៉ងនិងឱ្យអ្នកដទៃដល់នូវសេចក្តីវិនាសឡើយ ។
៣- សម្មាទិដ្ឋិ គំនិតយល់ឃើញត្រូវពិត តាមការពិត ហើយប្រកាន់ឡើងថាជាត្រូវមែន ។

អ្នកណាបានប្រព្រឹត្តត្រូវតាមកុសលកម្មបថទាំង ១០ ប្រការដូចបានពោលមកហើយនេះ អ្នកនោះនិងបានសេចក្តីសុខ សេចក្តីចំរើនក្នុងលោកទាំង ២ គឺក្នុងលោកនេះ នឹងបរលោកនាយជាប្រាកដ ។

ចប់បទបកិណ្ណកដោយសង្ខេបប៉ុណ្ណេះ

រីក្តីប្រយ័ត្ន មិនឱ្យភ្លាំងភ្លាត់ ទិបត្តិស្មារតី ជាផ្លូវអម្រឹត
ទិសដ្ឋឥតភ័យ ឥតទុក្ខសោកអ្វី កើតមានទៀតឡើយ ។
រីក្តីប្រហែស ស្មារតីភ្លេចធ្វេស គំនិតគោះតើយ ជាផ្លូវមច្ចុ
ស្លាប់កើតឥតស្បើយ ឥតកោះឥតត្រើយ វិលកើតវិលស្លាប់ ។
នរអ្នកណា មានចិត្តក្លៀវក្លា ប្រញិកប្រញាប់ ខំប្រឹងប្រព្រឹត្ត
ពិតតាមធម៌ច្បាប់ អ្នកនោះទោះស្លាប់ ហើយដូចនៅរស់ ។
នរអ្នកណា អាប់ឥតប្រាជ្ញា ប្រមាទស្រស់ៗ ភ្លេចភ្លាំងស្មារតី
រាល់ថ្ងៃទាំងអស់ អ្នកនោះនៅរស់ ដោយជកជង្ហើម ។
ព្រះពុទ្ធទ្រង់ប្រាប់ ថាដូចជាស្លាប់ ស្រេចហើយគួរខ្ពើម ទោះបីនៅរស់
ដោយសារជង្ហើម អ្នកប្រាជ្ញលោកខ្ពើម ស្មើរក្អួតចង្អោរ ។
ជនផងគួរគិត គួរផ្ចង់គំនិត គួរកាត់គួរកោរ គួរគេចជៀសចាង
គួររាងគួរស្ញោរ រំងាប់ចិត្តចោរ លួចប្លន់កុសល ។
យើងជាសាមញ្ញ នៅមានក្តីភ្លាញ់ គ្លាន់ខឹងរចល់ ក៏ពិតមែនហើយ
ប៉ុន្តែកុំខ្វល់ គួរប្រឹងតម្កល់ ចិត្តកុំប្រមាទ ។
គួរប្រុងប្រយ័ត្ន ស្មារតីកុំភ្លាត់ កុំភ្លេចឱ្យខាត អ្នកប្រាជ្ញទាំងឡាយ
មានព្រះជាអាទ៌ កុំឱ្យឃ្លៀងឃ្លាត ចាកធម៌សុចរិត ។

វត្តឧណ្ណាលោម ក្រុងភ្នំពេញ ថ្ងៃអង្គារ ទី២៣ កក្កដា ព.ស ២៥១២. គ.ស ១៩៦៨

សម្តេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ